សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit Et Des Sciences Economiques

Royal University of Law and Economic

សារណាបញ្ចប់ការសិក្សា

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ អាណត្តិទី៦

(ឆ្នាំ ២០១៨-២០២១)

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ខេង ង៉ែងហួរ**

កញ្ញា ទូច ល្មៀងហួរ

ណែនាំដោយ

លោក ឡាញ់ ជា

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit Et Des Sciences Economiques

Royal University of Law and Economic

សារណាបញ្ចប់ការសិក្សា

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ អាណត្តិទី៦

(ឆ្នាំ ២០១៨-២០២១)

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក ខេង ង៉ែងហួរ**

កញ្ញា ទូច ល្មៀងហួរ

ណែនាំដោយ

លោក ឡាញ់ ជា

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សេចក្តីថ្លែងអំណរគុណ

ជាបឋម យើងខ្ញុំ **ខេង វ៉ែងហួរ** និងកញ្ញា **ទូច លៀងហួរ** សូមសម្តែងនូវសេចក្តីគោរព និងកតញ្ញូតវេទីជូន ចំពោះ

លោកឪពុក ម៉ែង ហួយ អ្នកម្តាយ តូ សោភា និង **លោកឪពុក ហ៊ុន ទូច អ្នកម្តាយ តាំង ហ្គិចហុង** ដែលបានថែរក្សា ចិញ្ចឹមបីបាច់កូន តាំងពីចាប់កំណើតក្នុងផ្ទៃដល់ចម្រើនធំពេញវ័យ ប្រកបដោយភាពកក់ក្តៅ និងមេត្តាសន្តោសប្រណីដល់កូនជានិច្ច។ អ្នកមានគុណទាំងទ្វេស៊ូលះបង់កម្លាំងកាយ ចិត្ត ធនធាន និងសេចក្តីសុខផ្ទាល់ខ្លួន គ្រប់បែបយ៉ាងដើម្បីកូន ដោយពុំបានទាមទារអ្វីទាំងអស់ ដោយសុំតែម៉្យាងគឺចង់ឱ្យកូនមានសេចក្តីសុខក្នុងជីវិត និងក្លាយជាបុគ្គលល្អមួយរូបក្នុងសង្គម និងប្រកបដោយគន្លងធម៌។ លោកទាំងបួនបានខិតខំទូន្មានប្រៀនប្រដៅកូនឱ្យមានឥរិយាបទនិងអត្តចរិកល្អ ចេះគោរពគ្រូបាអាចារ្យ បងប្អូន ញាតិមិត្តជាដើម។ ជាពិសេសលោកអ្នកមានគុណ បានបញ្ជូនកូនទៅសាលារៀន ដែលជាឃ្លាំងបណ្តុះបណ្តាល បញ្ញាស្មារតីបំណិនជីវិត ដែលជាមរតកថ្លៃថ្លា និងមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ឱ្យកូនអាចរស់នៅក្នុង សង្គមនាពេលបច្ចុប្បន្ននេះ។

ជាមួយគ្នានេះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម បណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ លោកគ្រូ អ្នកគ្រូ ក៏ដូចជាសាស្ត្រាចារ្យ**ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្រៀន ផ្តល់ ដំបូន្មាន និងបទពិសោធន៍ល្អៗជាច្រើនដល់ពួកយើងខ្ញុំទាំងពីរ តាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់បរិញ្ញាបត្រ ប្រកបដោយភាពជោគជ័យមួយនេះ។

ខណៈពេលនេះដែល យើងខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះ **លោក ទឹម ជានូ អភិបាលនៃគណៈអភិបាលក្រុងច្បារមន ខេត្តកំពង់ស្ពឺ** ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរ បានចុះសិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធនឹង ប្រធានបទស្រាវជ្រាវ និងតែងតែផ្តល់ភាពងាយស្រួយដល់ពួកយើងខ្ញុំទាំងពីរ ក្នុងអំឡុងពេលចុះសិក្សាស្រាវជ្រាវ និងប្រមូលឯកសារ និងទិន្នន័យយកមកចងក្រងជាសៀវភៅមួយនេះឡើង។

នឹងសូមថ្លែងអំណរគុណជូនចំពោះ **លោក អ៊ុម ចាន់តារា នាយករដ្ឋបាលក្រុងច្បារមន ខេត្តកំពង់ស្ពឺ** ដែលបានជួយសម្របសម្រួលដល់យើងខ្ញុំទាំងពីរ ក្នុងការចុះសិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធនឹង ប្រធានបទស្រាវជ្រាវ។

ហើយក៏ឆ្លៀតឱកាសនេះសូមថ្លែងអំណរគុណដល់ **លោក ចាន់ រតនៈ ប្រធានអង្គភាពលទ្ធកម្ម ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និងលោកអនុប្រធាន** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការពន្យល់ណែនាំ និងផ្តល់នូវទិន្នន័យ ពាក់ព័ន្ធ នឹងដំណើការនៃកិច្ចលទ្ធកម្មសាធារណៈក្នុងក្រុងច្បារមន។

និងសូមសម្តែងនូវសេចក្តីអរគុណជាពិសេសជូនចំពោះ **លោកគ្រូ ឡាញ់ ដា** ដែលបានដឹកនាំក្នុងការសរសេរសារណា និងជួយណែនាំនិងផ្តល់ជាអនុសាសន៍ខ្លះៗ ប្រៀបបានដូចជាប្រទីបបង្ហាញផ្លូវ ដល់ពួកខ្ញុំទាំងពីរ បណ្តុះនូវគំនិតផ្តួតផ្តើមក្នុងការកសាងគម្រោង និងរចនាសម្ព័ន្ធស្រាវជ្រាវមួយ អស់ពីកម្លាំងកាយចិត្ត និង ក្នុងការរួមចំណែកមួយយ៉ាងធំធេងដែលជាហេតុនាំឱ្យសារណាមួយនេះសម្រេចបានជោគជ័យ។

និងដោយឡែកយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលេង ជូនចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និង គណៈកម្មការ ដែលបានជួយរៀបចំកម្មវិធីទ្រទ្រង់សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ និងបានចូលរួមសណ្តាប់ និងធ្វើការវាយតម្លៃការ ការពារសារណាបញ្ចប់ការសិក្សា ប្រកបដោយតម្លាភាព និងកិត្តិយសបំផុត។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរ បរសព្វសាធុការជូនដល់លោកឪពុកអ្នកម្តាយ រួមទាំងថ្នាក់ដឹកនាំក្រុង ច្បារមន ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ និងលោកគ្រូ អ្នកគ្រូ ទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសូមជួបប្រកបតែសេចក្តីសុខសុភមង្គលព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត ឡើយ។

រាជធានីភ្នំពេញថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៤

លោក ខេង វ៉ងហួរ និង កញ្ញា ទូច លៀងហួរ

អារម្ភកថា

ក្រោយពីការសិក្សាស្វែងយល់ទទួលបាននូវចំណេះវិជ្ជាលើមុខជំនាញរដ្ឋបាលសាធារណៈអស់រយៈពេល ០៤ឆ្នាំនៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានធ្វើឱ្យយើងខ្ញុំទទួលបាននូវពុទ្ធិជាច្រើនស្តីពីការគ្រប់គ្រងរដ្ឋបាល។ ក្តីស្រមៃមួយដែលបានញុំាងឱ្យយើងខ្ញុំ តាំងចិត្តក្នុងការសរសេរសារណាបញ្ចប់ឆ្នាំនេះ គឺការចង់បន្សល់ទុកនូវ ឯកសារ ចងក្រង និងស្រាវជ្រាវមួយដែលអាចជួយដល់យុវនិស្សិតជំនាន់ក្រោយអាចយកទៅសិក្សាបន្ត ក្នុងគោលបំណងតែ មួយគត់គឺ ការលើកកម្ពស់ធនធានមនុស្ស ក៏ដូចជាការចែករំលែកចំណេះដឹងដែលខ្លួនបានទទួលបានក្នុងអំឡុង ពេល០៤ឆ្នាំមកនេះ។ ត្បិតថាក្នុងការសិក្សាមុខជំនាញរដ្ឋបាលសាធារណៈ ចាំបាច់សិក្សាលើមូលដ្ឋានចំណេះដឹង នានាជាច្រើន ដែលបម្រើឱ្យការគ្រប់គ្រងរដ្ឋបាល ដូច្នេះជារឿងមិនអាចប្រកែកបាននិស្សិតគ្រប់រូបត្រូវខិតខំ និងបង្កើន សមត្ថភាពក្នុងការអានឯកសារឱ្យបានច្រើន។ តែបញ្ហាចោទនោះថាឯកសារ ទាំងនោះនៅមានការខ្វះខាត និងមានលក្ខណៈពិបាកស្វែងរកនៅឡើយណាមួយការផ្សព្វផ្សាយមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយទេ អាស្រ័យ ដូចនេះហើយឯកសារមួយចំនួនបានទទួលពីសំណាក់សាស្ត្រាចារ្យបង្រៀន និងការទាញយកឯកសាពីបរទេសជាដើម។ ដោយការមានឆន្ទៈដែលប្រកបដោយទស្សនៈវិស័យក្នុងការសិក្សាបន្ថែមពីការទទួលបានការបង្ហាត់បង្រៀន និងណែនាំយ៉ាងយកចិត្តទុកដាក់ ពីសំណាក់សាស្ត្រាចារ្យដែលមានជំនាញ បទពិសោធន៍ខ្ពស់ក្នុងវិស័យអប់រំ និងចូល រួមដោយផ្ទាល់ក្នុងវិស័យសាធារណៈផងទៀតនោះ ទើបនាំឱ្យយើងខ្ញុំសម្រេចបាននូវលទ្ធផលសិក្សាល្អប្រសើរដោយបានស្តែងចេញតាមរយៈការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្ររដ្ឋបាលសាធារណៈនេះ។

ខណៈដែលយើងខ្ញុំទទួលបានឱកាសដ៏ល្អក្នុងការសរសេរសារណាបញ្ចប់ការសិក្សាយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី << **ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្រុងច្បារមន អាណត្តិទី៦ (២០១៨ - ២០២១)>>** ដើម្បីសិក្សាស្រាវជ្រាវ។ អ្វីដែលជម្រុញយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវក៏ព្រោះតែយើងខ្ញុំយល់ថា **លទ្ធកម្មសាធារណៈ** គឺជាយន្តការមួយដើម្បីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិការដ្ឋឱ្យមានតម្លាភាព គណនេយ្យភាព សង្គតិភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការរួមចំណែកសន្សំសំចៃថវិការដ្ឋឱ្យកាន់តែប្រសើរឡើង ក្នុងគោលដៅរួមចំណែកបង្កើនទំនុកទុកចិត្តពីគ្រប់មជ្ឈដ្ឋាននៅក្នុងមូលដ្ឋានក្រុង ដែលបាននឹងកំពុងទទួលបានការរីកចម្រើនខាងវិស័យសេដ្ឋកិច្ចជាខ្លាំង។

ជាកិច្ចបញ្ចប់ យើងខ្ញុំរំពឹង និងសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងក្លាយទៅជាឯកសារមួយដែលសម្រួលដល់ការសិក្សារបស់ប្អូនៗជំនាន់ក្រោយ ដែលទាក់ទងនិងកិច្ចលទ្ធកម្មសាធារណៈ។ យើងខ្ញុំមាន

សេចក្តី សោមនស្សរីករាយ និងទទួលរាល់មតិរិះគន់បែបស្ថាបនា ដើម្បីញុំាងឱ្យស្មាដៃស្រោវជ្រាវមួយនេះកាន់តែមានភាពត្រឹមត្រូវ និងប្រកបដោយគុណប្រយោជន៍ខ្ពស់។

រាជធានីភ្នំពេញថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៤

លោក ខេង វ៉ាងហួរ និង កញ្ញា ទូច លៀងហួរ

មាតិកា

ទំព័រទី

ពាក្យគន្លឹះ IV

សេចក្តីផ្តើម ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ២

៣.គោលបំណងនៃការស្រាវជ្រាវ ២

៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ៣

៥.សារៈប្រយោជន៍នៃការស្រាវជ្រាវ ៣

៦.វិធីសាស្ត្រនៃការស្រាវជ្រាវ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៣

ជំពូកទី ១
រំលឹកទ្រឹស្តី

ផ្នែកទី១ ៖ បរិបទទូទៅនៃការអនុវត្តលទ្ធកម្មសាធារណៈ ៥

១.សាវតានៃលទ្ធកម្មសាធារណៈនៅកម្ពុជា ៥

២.និយមន័យ ៦

- ២.១.គោលបំណង ៦
- ២.២.អត្ថប្រយោជន៍នៃកិច្ចលទ្ធកម្មសាធារណៈ ៧
- ២.៣.ប្រភេទនៃកិច្ចលទ្ធកម្មសាធារណៈ ៧
- ២.៤.គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្មសាធារណៈ ៨

ផ្នែកទី២ វិធីសាស្ត្រលទ្ធកម្ម និងនីតិវិធីលទ្ធកម្មសាធារណៈ ១០

១.វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ១០

- ១.១.វិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ១០
- ១.២.វិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងដ៏ទៃទៀត ១១
- ១.៣.វិធីសាស្ត្រលទ្ធកម្មសាធារណៈដោយឡែក ១២

២.វិធីសាស្ត្រលទ្ធកម្មសាធារណៈសេវាទីប្រឹក្សា ១៣

២.១.ការជ្រើសរើសដោយផ្អែកលើគុណភាព ១៣
២.២.ការជ្រើសរើសដោយផ្អែកលើគុណភាព និងតម្លៃ ១៤
២.៣.វិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់ ១៥
២.៤.វិធីសាស្ត្រជ្រើសរើសផ្អែកលើតម្លៃទាបបំផុត ១៥
២.៥.វិធីសាស្ត្រជ្រើសរើសផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សា ១៦
២.៦.វិធីសាស្ត្រជ្រើសរើសលើមូលដ្ឋានប្រភពតែមួយ ១៦
២.៧.វិធីសាស្ត្រជ្រើសរើសទីប្រឹក្សាឯកត្តជន ១៦
៣.នីតិវិធីលទ្ធកម្មសាធារណៈលើទំនិញ សំណង់ និងសេវាកម្ម ១៦
៣.១.នីតិវិធីលទ្ធកម្មសាធារណៈសម្រាប់វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ១៦
៣.២.នីតិវិធីលទ្ធកម្មសាធារណៈសម្រាប់វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងដ៏ទៃទៀត ១៨
៣.៣.នីតិវិធីលទ្ធកម្មសាធារណៈសម្រាប់វិធីសាស្ត្រដេញថ្លៃដោយឡែក ១៨
៤.នីតិវិធីលទ្ធកម្មសាធារណៈសេវាទីប្រឹក្សា ១៩
៤.១.ដំណើរការនៃការចុះកិច្ចសន្យា ១៩
៤.២.ការបញ្ចប់កិច្ចសន្យាទីប្រឹក្សា ១៩
៤.៣.ថ្លៃទូទាត់នៃសេវាទីប្រឹក្សា ២១

ជំពូកទី២
ការគ្រប់គ្រងរដ្ឋបាលដែនដីក្រុងច្បារមន

ផ្នែកទី១ ៖ ទីតាំងភូមិសាស្ត្រ ២២
១.ស្ថានភាពទូទៅ ២២
២.ចំនួនប្រជាជនបច្ចុប្បន្ន ២២
៣.ការគ្រប់គ្រងការងារសន្តិសុខសាធារណៈ ២៣
ផ្នែកទី២ ៖ រចនាសម្ព័ន្ធគ្រប់គ្រង ២៤
១.រចនាសម្ព័ន្ធរដ្ឋបាលក្រុង និងសមាសភាពដឹកនាំ ២៤
១.១.រចនាសម្ព័ន្ធរដ្ឋបាលក្រុង ២៤
១.២.សមាសភាពដឹកនាំក្រុង ២៥
២.សមាសភាពនៃគណៈអភិបាល ២៦

២.១.ក្រុមប្រឹក្សាក្រុង ២៦
២.២.តួនាទីភារកិច្ចក្រុមប្រឹក្សាក្រុង ២៦

ជំពូកទី៣
ការអនុវត្តលទ្ធកម្មសាធារណៈក្រុងច្បារមន និងបញ្ហាប្រឈម

ផ្នែកទី១ ការរៀបចំ និងការអនុវត្តផែនការលទ្ធកម្មសាធារណៈ ២៨
១.គណៈកម្មាធិការលទ្ធកម្មសាធារណៈរបស់ក្រុង ២៨
២.អង្គភាពលទ្ធកម្មសាធារណៈ ២៨
៣.ការរៀបចំផែនការលទ្ធកម្ម ២៩
៤.ផែនការលទ្ធកម្មសាធារណៈអាណត្តិទី៦ និងការអនុវត្ត ៣១
៤.១.គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០១៨ ..... ៣១
៤.២.គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០១៩ ..... ៣១
៤.៣.គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២០ ..... ៣២
៤.៤គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ ..... ៣២
៤.៥.ការអនុវត្តផែនការលទ្ធកម្មសាធារណៈក្រុង ៣៣
៤.៦.លទ្ធផលនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ៣៣
៥.នីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មសាធារណៈ ៣៤
៥.១.នីតិវិធីនៃការប្តឹងតវ៉ាលទ្ធកម្មសាធារណៈ ៣៤
៥.២.ការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មសាធារណៈ ៣៥
ផ្នែកទី២ បញ្ហាប្រឈម និងដំណោះស្រាយ ៣៦
១.បញ្ហាប្រឈម ៣៦
២.ដំណោះស្រាយ ៣៦
សេចក្តីសន្និដ្ឋាន ៣៧
អនុសាសន៍ ៣៨
ឯកសារយោង .....
ឧបសម្ព័ន្ធ .....

ពាក្យគន្លឹះ

ពាក្យគន្លឹះ

លទ្ធកម្ម : គឺជាការរកបាននូវទំនិញ និងសេវាកម្មពាក់ព័ន្ធ ឬជាការជួលអ្នកទទួលការ សម្រាប់ការសាង សង់ ជួសជុល តាមរយៈវិធីសាស្ត្រដែលបានរៀបរាប់ក្នុងវិធាន និងបញ្ញត្តិលទ្ធកម្មសាធារណៈ។

លទ្ធកម្មសាធារណៈ : គឺជាលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ/សង្កាត់ និង សហគ្រាសសាធារណៈលក្ខណៈរដ្ឋបាល។

ទំនិញ : គឺជាវត្ថុរាវ រឹង ឬឧស្ម័ន ដែលមានតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ច ដូចជា គ្រឿងចក្រឧបករណ៍ សម្ភារ បរិក្ខារ និងផលិតផលផ្សេងៗទៀតរួមទាំងអគ្គីសនីផងដែរ។

សំណង់ : រាល់សកម្មភាពពាក់ព័ន្ធ និងការងារសាងសង់ ការជួសជុល ការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការ បូម និងការងារប្រហាក់ប្រហែលដែលបង្កើតឱ្យមានការប្រើប្រាស់កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារ និង បច្ចេកវិទ្យា។

ឡូត៍លទ្ធកម្ម : គឺជាការប្រមូលផ្តុំទំនិញ ឬសំណង់ដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬស្រដៀងគ្នាជាក់ ចូល ក្នុងក្រុមតែមួយសម្រាប់ធ្វើលទ្ធកម្មតែមួយលើក។

កញ្ចប់លទ្ធកម្ម : គឺជាការប្រមូលផ្តុំឡូត៍លទ្ធកម្មដែលមានភាពប្រហាក់ប្រហែលគ្នា ឬស្រដៀងគ្នាបញ្ចូលក្នុង កញ្ចប់ធំតែមួយ សម្រាប់ធ្វើលទ្ធកម្មតែមួយលើក។

សេវាកម្ម : ជាសកម្មភាពនៃការប្រើកម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬបច្ចេកវិទ្យាដែលនាំមកនូវផលប្រយោជន៍ ដល់ ស្ថាប័នសាធារណៈប៉ុន្តែមិនរាប់បញ្ចូលក្នុងការងារសាងសង់ និងមុខរបររបស់សេវាប្រឹក្សាទេ។

សេវាទីប្រឹក្សា : គឺជាសេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សា ឬក៏ជាទីប្រឹក្សាឯកត្តជន ដែលពាក់ព័ន្ធ ទៅ និងគម្រោងណាមួយ ឬសម្រាប់ពង្រឹងស្ថាប័ន។

ទីប្រឹក្សា : ជាក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹកក្សាឯកជនដែលមានមុខរបរផ្តល់នូវសេវាទីប្រឹក្សា។

អ្នកម្ចាស់ការ : គឺជាស្ថាប័នសាធារណៈ ដែលចុះកិច្ចសន្យាស្តីពីការសាងសង់ ឬសេវាកម្មជួលជាមួយ អ្នកទទួលការ។

អ្នកទទួលការ : គឺឯកត្តជនឬក្រុមហ៊ុនដែលចុះកិច្ចសន្យាលើការសាងសង់ឬសេវាកម្មជួលជាមួយអ្នកម្ចាស់ការ។

អ្នកទិញ : គឺជាស្ថាប័នសាធារណៈដែលបានចុះកិច្ចសន្យាទិញទំនិញជាមួយអ្នកផ្គត់ផ្គង់។

អ្នកផ្គត់ផ្គង់ : គឺជាបុគ្គល ឬក្រុមហ៊ុនដែលចុះកិច្ចសន្យាលក់ទំនិញជាមួយអ្នកទិញ។

ការសន្សំសំចៃ : គឺជាការសម្រេចបាននូវតម្លៃ ល្អបំផុតឆ្លងតាមរយៈការប្រកួតប្រជែងដោយយុត្តិធម៌។

តម្លាភាព : ជាការបំពេញករណីយកិច្ច ឱ្យបានត្រឹមត្រូវ និងស្មោះត្រង់ក្នុងដំណើរការអនុវត្តកិច្ចលទ្ធកម្ម។

គណនេយ្យភាព : ជាការធានាឱ្យមានការទទួលខុសត្រូវទាំងឡាយណា ដែលមានការជាប់ពាក់ព័ន្ធ និងដំណើរការអនុវត្តកិច្ចលទ្ធកម្ម។

សមភាព : ផ្អែកតាមទម្រង់ឯកភាពតែមួយលើគោលនយោបាយ និងនីតិវិធីលទ្ធកម្មបង្កើតឱ្យមានភាពស្មើគ្នាសម្រាប់ការប្រកួតប្រជែង។

ប្រសិទ្ធភាព : មានន័យថា ដំណើរការនៃកិច្ចលទ្ធកម្មទំនិញ សំណង់ និងសេវាកម្មត្រូវប្រព្រឹត្តទៅដោយ រលូនតាមវិធីសាស្ត្រ និងនីតិវិធីនៃលទ្ធកម្មសាធារណៈហើយឆ្លើយតបពេញលេញទៅនឹងតម្រូវការ លក្ខខណ្ឌបច្ចេកទេស បរិមាណ គុណភាព ពេលវេលា សេវាកម្ម និងតម្លៃ។

សុចរិតភាព : ជាការជំរុញឱ្យដំណើរការនៃកិច្ចលទ្ធកម្ម ប្រកបទៅដោយតម្លាភាព ស្មើភាព និងមានការ ទុកចិត្តពីសាធារណៈជន។

ក្រមសីលធម៌វិជ្ជាជីវៈ : មានន័យថា អ្នកចូលរួមពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មត្រូវយល់ដឹង និងអនុវត្តដោយស្មោះត្រង់តាមបញ្ញត្តិជាធរមាន និងអនុវត្តឱ្យបានត្រឹមត្រូវ តាមតួនាទី និងមុខងាររបស់ខ្លួន។

អំពើពុករលួយ : សំដៅដល់ការសូក ឬទទួលវត្ថុមានតម្លៃ ដើម្បីធ្វើឱ្យមានឥទ្ធិពល លើសកម្មភាពមន្ត្រីរាជការសាធារណៈក្នុងដំណើរការជ្រើសរើស ប្រគល់កិច្ចសន្យា ឬក្នុងការអនុវត្តកិច្ចសន្យា។

អំពើបន្លំ : គឺជាការបកស្រាយបំភ្លៃ ហេតុការណ៍ ដើម្បីធ្វើឱ្យមានឥទ្ធិពល លើដំណើរការរាយតម្លៃក្នុងការ ប្រគល់កិច្ចសន្យា និងការចូលរួមចំណែកក្នុងអំពើឃុបឃិតជាមួយអ្នកដេញថ្លៃ ឬទីប្រឹក្សា ដើម្បីឱ្យខូច ប្រយោជន៍រាជរដ្ឋាភិបាល។

អំពើឃុបឃិត : សំដៅដល់ផែនការ ឬជាការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរ ឬច្រើនដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិត និងតម្លៃគ្មានលក្ខណៈប្រកួតប្រជែង ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយ ក្នុងដំណើរការដេញថ្លៃ ឬជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

អំពើបង្ខិតបង្ខំ : សំដៅដល់ការហាមឃាត់ ឬការគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោលធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិរបស់បុគ្គលដើម្បីធ្វើឱ្យមានឥទ្ធិពលក្នុងការចូលរួមនៅក្នុងដំណើរការកិច្ច លទ្ធកម្មសាធារណៈរបស់បុគ្គលនោះ ឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

សំណើដេញថ្លៃ: គឺជាការដាក់ឯកសារដេញថ្លៃដើម្បីផ្តត់ផ្គង់ទំនិញសេវាកម្ម ឬធ្វើការសាងសង់ជួសជុល ដើម្បីធ្វើឡើងតាមលក្ខខណ្ឌកំណត់ដោយអ្នកទិញ ឬអ្នកម្ចាស់ការ។

បុរេលក្ខណៈសម្បត្តិ : គឺជាការវាយតម្លៃលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់អ្នកផ្គត់ផ្គង់ឬអ្នកទទួល ការក្នុងគោលបំណងជ្រើសរើសអ្នកដែលបានអាចអញ្ជើញឱ្យចូលរួមក្នុងការដេញថ្លៃបាន។

លក្ខណៈសម្បត្តិតាមក្រោយ : គឺជាសកម្មភាពវាយតម្លៃឡើងវិញនូវលក្ខណៈសម្បត្តិបច្ចេកទេស និងហិរញ្ញវត្ថុ អ្នកដែលមានតម្លៃថោកជាងគេបំផុតដើម្បីបញ្ជាក់ឱ្យដឹងថា តើមានសមត្ថភាពអនុវត្តកិច្ចសន្យាដែរឬទេ?

កិច្ចសន្យា : គឺជាកិច្ចព្រមព្រៀងរវាងអ្នកទិញ និងអ្នកផ្គត់ផ្គង់ដើម្បីផ្តល់ទំនិញ ឬប្រាក់រវាងមិត្តអ្នកម្ចាស់ការ និងអ្នកទទួលការដើម្បីអនុវត្តការងារសាងសង់ជួសជុលជួលឬជួលសេវាក្នុងលក្ខខណ្ឌដែលព្រមព្រៀដោយ ភាគីទាំងពីរ។

សេចក្តីផ្តើម

សេចក្តីផ្តើម

១.ចំណាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងទទួលផលជាផ្លែផ្កាពីសន្តិភាពដែលផុសចេញពីនយោបាយឈ្នះឈ្នះ ដោយការអភិវឌ្ឍផ្តើមចេញពីគោលនយោបាយបើកចំហរជើងមេឃ ទទួលស្វាគមន៍រាល់អ្នកវិនិយោគ ការបង្កើតប្រព័ន្ធអភិបាលកិច្ចល្អ និងរបៀបអនុវត្តន៍ប្រព័ន្ធនេះឱ្យកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ កម្ពុជាបានប្រើអស់សក្តានុពលស្ថាប័ន មន្ត្រីរាជការ និងធនធានរបស់ខ្លួន ដើម្បីជំនះបញ្ហាប្រឈមនានាក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីជម្រុញឱ្យកាន់តែប្រសើរឡើងនូវសមភាពសង្គមនិងកាត់បន្ថយភាពក្រីក្រក្នុងសង្គមជាតិ។ ដូចយើងបានដឹងហើយថានៅក្នុងមុំ នៃយុត្តិសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា អភិបាលកិច្ចល្អគឺវិស័យស្នូលមួយដែល រាជរដ្ឋាភិបាលយកចិត្តទុកដាក់។ អត្ថន័យដែលបានបង្កប់ក្នុងពាក្យថាអភិបាលកិច្ចល្អនេះ យើងបានឃើញអំពីការធ្វើកំណែទម្រង់វិស័យរដ្ឋបាលសាធារណៈដែលគ្រប់មន្ត្រី និងបុគ្គលិកសាធារណៈនៅគ្រប់ពេលវេលាទាំងអស់ត្រូវតែទទួលខុសត្រូវចំពោះប្រជាជន បម្រើប្រជាជនក្នុងទំនួលខុសត្រូវខ្ពស់ មានសច្ចៈភាព ភក្តីភាព និងប្រសិទ្ធភាព ព្រមទាំងត្រូវបំពេញការងារ ប្រកបដោយមនសិការស្នេហា មាតុភូមិ យុត្តធម៌ និងរស់នៅក្នុងជីវភាពសាមញ្ញ។

ជាការពិតណាស់មន្ត្រីរាជការសាធារណៈត្រូវមានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋ ដើម្បីធានាថាគ្រប់សកម្មភាពរបស់មន្ត្រីរាជការសាធារណៈ គឺសុទ្ធតែដើម្បីបម្រើផលប្រយោជន៍ទូទៅ ។

ដោយយោងលើមូលបញ្ហា និងកត្តាសត្យានុម័តទាំងអស់នេះហើយទើបក្នុងសកម្មភាពកិច្ចលទ្ធកម្មសាធារណៈនៅកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បំផុត ដោយបានដល់ការបញ្ចូល សកម្មភាពនេះនៅក្នុង យុត្តិសាស្ត្រចតុកោណនៃមុំស្នូលនៃអភិបាលកិច្ចល្អ ព្រោះថាយន្តការនៃការបង្កើតឱ្យមាននូវសកម្មភាពលទ្ធកម្មសាធារណៈ ដែលជាតម្រូវការប្រើប្រាស់ផ្នែកសម្ភារ បច្ចេកទេស ឬតម្រូវការនានា នោះ វាបានធ្វើឱ្យរាជរដ្ឋាភិបាលអាចពង្រឹង និងលើកកម្ពស់ការគ្រប់គ្រង ការចំណាយថវិការដ្ឋឱ្យកាន់តែមាន តម្លាភាព សុក្រឹត្យភាព គណនេយ្យភាព សង្គតិភាព និងប្រសិទ្ធភាពខ្ពស់។ ម៉្យាងវិញទៀតលទ្ធកម្មសាធារណៈ ក៏បានរួមចំណែកក្នុងការសន្សំសំចៃថវិការដ្ឋ ឱ្យបានកាន់តែប្រសើរឡើង ក្នុងគោលដៅរួមចំណែកបង្កើនភាព ជឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន។ ហេតុដូចនេះតាមរយៈសកម្មភាពចំណាយរបស់ស្ថាប័នអនុវត្តន៍ថវិកា ចាំបាច់ត្រូវ អនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈ តាមទំហំទឹកប្រាក់កំណត់ដោយលិខិតបទដ្ឋាន គតិយុត្តជាធរមាន។ ចំពោះប្រធានបទ **"ការអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ អាណត្តិទី៦ (ឆ្នាំ ២០១៨ -២០២១)** "ពិតជាមានសារៈសំខាន់បំផុតចំពោះសិស្ស និស្សិត ក៏ដូចជាអ្នកសិក្សាទូទៅបានសិក្សាស្វែងយល់អំពីភាពចាំបាច់នៃ

ការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈនីតិវិធី និងគោលការណ៍សំខាន់ៗទាក់ទងទៅនឹង កិច្ចលទ្ធកម្ម សាធារណៈនៅថ្នាក់ក្រោមជាតិ។

ជាសក្ខីភាពអង្គភាពលទ្ធកម្មសាធារណៈនៅក្រុងច្បារមន ត្រូវបានបង្កើតឡើងដោយការធ្វើកំណែទម្រង់ យ៉ាងស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដែលបាន អនុញ្ញាត ឱ្យក្រុងច្បារមន ទទួលបាននីតិសម្បទាក្នុងការអនុវត្តកិច្ចលទ្ធកម្ម លើដំណើរការសកម្មភាពការទិញទំនិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងសេវាទីប្រឹក្សា ដែលសុទ្ធតែត្រូវធ្វើការចំណាយ ។ ដោយហេតុ ថាការអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈនៅក្រុងច្បារមន មានលក្ខណៈថ្មីថ្មោងដូច្នេះនៅក្នុងការ អនុវត្តន៍បានជួប ប្រទះនូវបញ្ហាមួយចំនួនដូចជា ធនធានមនុស្សសម្រាប់បំពេញការងារ ការអនុវត្តន៍តាមគោលការណ៍នៅមាន កម្រិត អាស្រ័យដូច្នេះហើយទើបានជាយើងខ្ញុំទាំងពីរសម្រេចលើកយកប្រធានបទនេះមកធ្វើការ សិក្សាស្រាវជ្រាវ ឱ្យកាន់តែស៊ីជម្រៅ និងច្បាស់លាស់ទៅលើបញ្ហាដែលជួបប្រទះ ក្នុងដំណើរការនៃកិច្ចលទ្ធកម្ម និងផ្តល់ជា យោបល់កែលម្អដើម្បីឱ្យការអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈនៅក្រុងច្បារមន គោរព និងអនុលោមតាមវិធាន គោលការណ៍ និងបទបញ្ជិត្តដែលបានកំណត់ ឱ្យកាន់តែប្រសើរឡើងជាលំដាប់។

២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ការអនុវត្តន៍ កិច្ចលទ្ធកម្មសាធារណៈ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ អាណត្តិទី៦ (ឆ្នាំ២០១៨ -២០២១)បានលើកនូវបញ្ហាមកចោទសួរ ទាក់ទងទៅនិង៖

តើការអនុវត្តន៍លទ្ធកម្មសាធារណៈនៅក្រុងច្បារមន មាននីតិវិធី និងប្រព្រឹត្តទៅយ៉ាងដូចម្តេច?

តើក្នុងនាមជាអ្នកទទួលបន្ទុកអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈត្រូវធ្វើដូចម្តេចដើម្បីឱ្យដំណើរការនៃកិច្ចលទ្ធកម្ម សាធារណៈទទួលបានប្រសិទ្ធភាពខ្ពស់?

៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងបំផុតនៃការសិក្សាស្រាវជ្រាវនេះគឺ ដើម្បីបង្ហាញអំពីគុណប្រយោជន៍នៃការអនុវត្ត កិច្ចលទ្ធកម្មសាធារណៈ ដែលជាព័ត៌មានសម្រាប់គ្រប់ភាគីដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈក៏ដូចជា អ្នក សិក្សាទូទៅ ។ សៀវភៅនេះបង្ហាញពី វឌ្ឍនភាពនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅថ្នាក់ក្រោមជាតិ បញ្ហាប្រឈមនានាដែលអាចជួបប្រទះក្នុងអំឡុងពេលការអនុវត្តកិច្ចលទ្ធកម្មនិងរួមចំណែកផ្តល់ជូននូវយោបល់ ដែលសមស្របណាមួយដើម្បីរួមចំណែកដោះស្រាយបញ្ហា និងផ្តល់ជាអនុសាសន៍កែលម្អលើចំណុចខ្វះខាត ក្នុង គោលបំណងតែមួយគត់គឺ ធានាដល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈដោយភាពត្រឹមត្រូវ។

៤. ចំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវចំពោះប្រធានបទ "**ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ អាណត្តិទី៦ (ឆ្នាំ២០១៨-២០២១)**" យើងខ្ញុំសិក្សាតែទៅលើការរៀបចំ និងនីតិវិធីនៃកិច្ចលទ្ធកម្ម តួនាទីនិងភារៈ កិច្ចរបស់អង្គភាពទទួលបន្ទុកអនុវត្តកិច្ចលទ្ធកម្ម ផលវិជ្ជមាន បញ្ហាប្រឈម និងដំណោះស្រាយ ក្នុងដំណើរការ អនុត្តន៍កិច្ចលទ្ធកម្មសាធារណៈក្នុងមូលដ្ឋានក្រុងច្បារមនតែប៉ុណ្ណោះ។ ចំណែកឯដែនកំណត់នៃការស្រាវជ្រាវនេះវិញ គឺយើងខ្ញុំកំណត់យកក្នុងអាណត្តិទី៦ (ឆ្នាំ ២០១៨-២០២១)។

៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

នៅក្នុងដំណើរការលទ្ធកម្មសាធារណៈគឺជួយជម្រុញឱ្យការអភិវឌ្ឍមានប្រសិទ្ធភាពក៏ដូចជា ជ្រោមជ្រែងដល់ការអនុវត្តការងាររបស់អាជ្ញាធររដ្ឋ និងអ្នកដែលជាប់កាតព្វកិច្ចការងារសាធារណៈ ប្រកបដោយវិជ្ជាជីវៈ តម្លាភាព និងគិតដល់ប្រយោជន៍សាធារណៈជាចម្បង។

ខ្លឹមសារសំខាន់ៗនៅក្នុង សារណានេះ នឹងបង្ហាញដល់អ្នកអានអំពីទស្សនទាន និងដំណើរការលទ្ធកម្មសាធារណៈក្នុងកិច្ចអភិវឌ្ឍន៍ និងឱកាសដែលអាចឱ្យប្រជាពលរដ្ឋចូលរួមយ៉ាងសកម្មជាមួយរដ្ឋ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ ក្នុងការកសាងសង្គមកម្ពុជាយើង ឱ្យក្លាយទៅជាសង្គមមួយ ប្រកបទៅដោយ បរិយាប័នបាន។ សង្គមមួយល្អបានលុះត្រាតែសង្គមនោះត្រូវមានគណនេយ្យភាពដែលជាធាតុដ៏សំខាន់មួយ ក្នុងការគ្រប់គ្រងរដ្ឋដោយផ្អែកតាមគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ។

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ ត្រូវបានបង្កើតឡើងដោយការប្រមូលផ្តុំនូវ

- ឯកសារកិច្ចដំណើរការលទ្ធកម្មសាធារណៈនៅថ្នាក់ក្រោមជាតិ
- ទិន្នន័យនៃរបាយការណ៍បូកសរុបសមិទ្ធិផលប្រចាំឆ្នាំនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង ព្រមទាំងច្បាប់និងបទដ្ឋានគតិយុត្ត
- ការស្រាវជ្រាវបន្ថែមជាមួយការប្រមូលយកព័ត៌មានមួយចំនួនទៀត ដែលបានមកពីការសិក្សារៀនសូត្រកន្លងមក
- និងការចុះសិក្សាស្រាវជ្រាវផ្ទាល់នៅក្រុងច្បារមន ផងដែរ។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានបែងចែកជា **០៣**ជំពូករួមមាន ៖

ជំពូកទី១៖ រំលឹកទ្រឹស្តី

ជំពូកទី២៖ រដ្ឋបាលដែនដីក្រុងច្បារមន

ជំពូកទី៣៖ ការអនុវត្តលទ្ធកម្មសាធារណៈក្រុងច្បារមន និងបញ្ហាប្រឈម នៃកិច្ចលទ្ធកម្ម សាធារណៈនៅក្នុងក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

ជំពូកទី១

រំលឹកគ្រឹស្តី

ជំពូកទី១
រំលឹកទ្រឹស្តី

ផ្នែកទី១ ៖ បរិបទទូទៅនៃការអនុវត្តលទ្ធកម្មសាធារណៈ

១. សាវតានៃលទ្ធកម្មសាធារណៈនៅកម្ពុជា

មុនការមកដល់នៃរបបអាណានិគមបារាំង លទ្ធកម្ម ឬលទ្ធកម្មសាធារណៈនៅកម្ពុជាពុំមានឯកសារបញ្ជាក់ពីការអនុវត្តនៅក្នុងសង្គមខ្មែរ ឬអាចនិយាយម៉្យាងទៀតថា ពុំអាចរកឯកសារបញ្ជាក់បានឡើយ។ ប៉ុន្តែអនុសញ្ញា បារាំង-ខ្មែរ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៨៨៤ គឺជាការបើកផ្លូវមួយឆ្ពោះទៅរកការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សាធារណៈរបស់ប្រទេសកម្ពុជា។ បន្ទាប់ពីការកាន់កាប់ និងគ្រប់គ្រងប្រទេសកម្ពុជាបានជិតកន្លះសតវត្សដោយរដ្ឋបាល អាណានិគមបារាំងរួចមក យើងឃើញមានបទបញ្ញត្តិដែលទាក់ទងដល់ការអនុវត្តកិច្ចលទ្ធកម្ម ដែលនៅពេលនោះត្រូវ បានគេហៅថា៖ " **ការដេញថ្លៃ ឬការដេញតថ្លៃ ឬជាវលក់ដោយដេញថ្លៃ** " ដូចមានចែងក្នុងប្រការ២៨ និងប្រការ២៩ នៃព្រះរាជប្រកាសចុះថ្ងៃទី១ ខែដេសម(ធ្នូ) ឆ្នាំ១៩១៦ និងប្រកាសអារេតចុះថ្ងៃទី៥ ខែដេសម(ធ្នូ) ឆ្នាំ១៩១៦ ជាតឹកតាងស្រាប់។

ចំពោះរបបសង្គមរាស្ត្រនិយម និងរបបសាធារណរដ្ឋខ្មែរ ក៏ពុំទាន់អាចរកបាននូវឯកសារគតិយុត្តដែលទាក់ទងដល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងរបបនយោបាយទាំងពីរខាងលើនេះបាននៅឡើយដែរ។

ដោយឡែកចំពោះកិច្ចលទ្ធកម្មសាធារណៈ ឬការដេញថ្លៃជាសាធារណៈ បានចាប់កំណើតឡើងវិញជាថ្មីម្តងទៀតនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា តាមរយៈសេចក្តីសម្រេចលេខ៨៤ ស.ស.រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ១៩៨៨ ស្តីពីគោលការណ៍ដាក់ឱ្យដេញថ្លៃលើការធ្វើអាជីវកម្មដាក់ដោយចាប់កូនត្រីប្រា (ជាកិច្ចលទ្ធកម្មចំណូល) លើក លែងតែកិច្ចលទ្ធកម្មចំណាយ ពុំអាចរកបានឯកសារដូចគ្នា។

បន្ទាប់ពីការបោះឆ្នោតជាសកលដែលរៀបចំឡើងដោយអ៊ុនតាក់នាឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រង លទ្ធកម្មសាធារណៈ ដែលទាក់ទងដល់ការប្រតិបត្តិការចំណាយធនធានសាធារណៈរបស់ប្រទេស។

ដើម្បីឱ្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈកាន់តែមានភាពល្អប្រសើរជាងមុន និងឆ្លើយតបបានតាមតម្រូវការប្រើប្រាស់របស់សង្គម និងគោលនយោបាយរបស់រដ្ឋ ជាថ្មីម្តងទៀតរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ ដោយមានលក្ខណៈល្អិតល្អន់ស៊ីជម្រៅ គ្រប់ជ្រុងជ្រោយ និងមានការទទួលខុសត្រូវខ្ពស់ ចំពោះការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅតាមក្រសួង ស្ថាប័នសាធារណៈនានា។[1]

ដើម្បីធានាដល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងការសន្សំសំចៃ ព្រះរាជក្រមនស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ប្រកាសឱ្យប្រើច្បាប់ស្តីពី លទ្ធកម្មសាធារណៈ ជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធាន នីតិវិធី សេចក្តីណែនាំ

[1] -សៀវភៅលទ្ធកម្មសាធារណៈនៅកម្ពុជា ស្រាវជ្រាវដោយ ឡាញ់ ដា (ទំព័រ១) បោះពុម្ពលើកទី១ ឆ្នាំ២០២២

ព្រមទាំងការធ្វើវិសហមជ្ឈការលទ្ធកម្មដែលទាក់ទងដល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោម ជាតិផងដែរ។

ទន្ទឹមនេះ បទដ្ឋានគតិយុត្តសម្រាប់អនុវត្តន៍ និងគ្រប់គ្រងគម្រោងលទ្ធកម្មដែលប្រើប្រាស់ហិរញ្ញប្បទាន ដោយដៃគូរអភិវឌ្ឍន៍ នៅដាច់ដោយឡែកពីបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រង និងអនុវត្តគម្រោងលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋ។ ចំណែកឯយន្តការទទួល និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម នៅមិនទាន់មានភាពឯករាជ្យ និងរបបដាក់ទោសទណ្ឌច្បាស់លាស់នៅឡើយ។

២. និយមន័យ

- **ក្នុងន័យច្បាប់៖**
  - ការបានក្លាយជាកម្មសិទ្ធិការនៃវត្ថុ ឬសម្បត្តិណាមួយ តាមរបៀបណាមួយដូចជាការទិញ អច្ចំយទានជាដើម។ ការដែលបុគ្គលម្នាក់ក្លាយជាអ្នកទទួលអត្រានុកូលដ្ឋានថ្មី។
- **ក្នុងន័យសេដ្ឋកិច្ច៖**
  - ការបានទទួលវត្ថុអ្វីមួយដោយលំបាក និងដោយប្រុងប្រយ័ត្ន ប្រយ័ត្នប្រយែង។
  - ការទទួល និងរៀបចំដំណើរការដេញថ្លៃសាធារណៈនូវការដ្ឋានសំណង់ ឬទំនិញច្រើន។[2]
- **ក្នុងន័យគតិយុត្តិ៖**
  - កិច្ចលទ្ធកម្មសាធារណៈ សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល អង្គភាពស្វ័យភាពហិរញ្ញវត្ថុដ៏ទៃទៀត និងដៃគូរឯកជនសាធារណៈ។
  - លទ្ធកម្ម ការបានឡើងជាភោគី ឬជាកម្មសិទ្ធិការនៃវត្ថុណាមួយ ដោយការងារខ្លួនក្តី ដោយទិញក្តី ដោយដូរក្តី ដោយសន្តតិកម្មក្តី។[3]

២.១ គោលបំណង

ដើម្បីធានាដល់ការប្រើប្រាស់ថវិកាជាតិឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព និងចំគោលដៅរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅទៅលើប្រព័ន្ធមុខងារសាធារណៈនៅកម្ពុជាទើបក្នុងនីតិកាលទីបួននៃរាជរដ្ឋាភិបាល បានដាក់ចេញនូវយុត្តិសាស្ត្រនៃកំណែទម្រង់លទ្ធកម្មសាធារណៈក្នុងគោលបំណងរឹតបន្តឹងទៅលើការចំណាយថវិកាជាតិ តាមរយៈការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

[2] -សៀវភៅសន្ធានុក្រមបច្ចេកស័ព្ទទំនើប(ទំព័រ១៨១) បោះពុម្ពផ្សាយដោយសម្ព័ន្ធនិស្សិតខ្មែរមកពីបរទេស "លើដៃខ្មែរ" ភ្នំពេញ ១៩៩៨។

[3] -សន្ធានុក្រមភ្ជាប់ជាមួយនឹងច្បាប់ភូមិបាលចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

២.២. អត្ថប្រយោជន៍នៃកិច្ចលទ្ធកម្មសាធារណៈ

ការអនុវត្តលទ្ធកម្មសាធារណៈបានត្រឹមត្រូវ តាមគោលការណ៍ ណែនាំ និង អនុលោមទៅតាមបទដ្ឋានច្បាប់ចែងជាធរមាននោះ នឹងជម្រុញឱ្យមាននូវគុណប្រយោជន៍ដូចជា៖

- សន្សំសំចៃថវិកាជាតិ
- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកាជាតិ
- កាត់បន្ថយ និងលុបបំបាត់អំពើពុករលួយ
- ទទួលបានការជឿទុកចិត្តពីសំណាក់សាធារណៈជន ជុំវិញការប្រើប្រាស់ ឬការចំណាយថវិការបស់រដ្ឋ ទៅលើសកម្មភាពរបស់មន្ត្រីរាជការប្រចាំថ្ងៃ
- ធានាបាននូវ ផលិតផល ឬសេវាកម្មដែលល្អ និងបម្រើផលប្រយោជន៍ទូទៅ
- ឆ្លើយតបទាន់ពេលវេលា និងចំគោលដៅនៃតម្រូវការសាធារណៈ
- បង្ហាញពីគណនេយ្យភាព តម្លាភាពរបស់មន្ត្រីរាជការសាធារណៈ
- ធានាដល់ការផ្គត់ផ្គង់តម្រូវការសាធារណៈបានគ្រប់គ្រាន់និងប្រកបដោយគុណភាពនិងនាំមកនូវការអភិវឌ្ឍប្រកបដោយបរិយាប័ន។

២.៣. ប្រភេទនៃកិច្ចលទ្ធកម្មសាធារណៈ

លទ្ធកម្មសាធារណៈនៅកម្ពុជា ត្រូវបានបែងចែកជា៤ ប្រភេទដែលនៅក្នុងនោះមានដូចជា ៖

- លទ្ធកម្មសំណង់
- លទ្ធកម្មសេវាកម្ម
- លទ្ធកម្មទំនិញ
- និងលទ្ធកម្មសេវាទីប្រឹក្សា។

- **លទ្ធកម្មសំណង់ ៖** គឺសំដៅទៅលើសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងការងារសាងសង់ការជួសជុលការធ្វើឡើងជាថ្មី ការដំឡើងការជីក ការបូម និងការងារប្រហាក់ប្រហែលដែលបង្កើតឱ្យមានការប្រើប្រាស់ កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារ និងបច្ចេកវិទ្យា ។[4]
- **លទ្ធកម្មសេវាកម្ម ៖** គឺជាសកម្មភាពទាំងឡាយណាដែល ពាក់ព័ន្ធទៅនឹងការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬបច្ចេកវិទ្យាដែលនាំមកនូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់ និងសេវាទីប្រឹក្សាទេ ។

[4] -សៀវភៅលទ្ធកម្មសាធារណៈនៅកម្ពុជា ស្រាវជ្រាវដោយ ឡាញ់ ដា (ទំព័រ៤១-៤២) បោះពុម្ពលើកទី១ ឆ្នាំ២០២២

- **លទ្ធកម្មសម្ភារឬទំនិញ** ប្រភេទលទ្ធកម្មទំនិញគឺសំដៅលើ វត្ថុរាវ រឹង ឬជាឧស្ម័ន ដែលមានតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ច ដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារ បរិក្ខារគ្រឿងឧបភោគ បរិភោគ ឱសថ និងផលិតផលផ្សេងៗ រួមទាំងអគ្គិសនី ផងដែរ។
- **លទ្ធកម្មសេវាទីប្រឹក្សា** លទ្ធកម្មសេវាទីប្រឹក្សាអាចជ្រើសរើសយកមកដើម្បីផ្តល់នូវសេវាឯកទេសក្នុងការអនុវត្តគម្រោង ឬកិច្ចសន្យាសំខាន់ៗ ឬផ្តល់ជំនួយ ឬយោបល់ជំនាញ ក្នុងការងារពង្រឹងស្ថាប័ន ឬសមត្ថភាពស្ថាប័ន។ ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សា ឬជាឯកត្តជន។[5]

២.៤. គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្មសាធារណៈ

ក. គោលការណ៍សន្សំសំចៃ

គោលការណ៍នេះមានកម្មវត្ថុចម្បងគឺ ដើម្បីឱ្យមន្ត្រីរាជការទទួលបន្ទុកកិច្ចលទ្ធកម្មត្រូវប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីរួមចំណែកក្នុងការប្រើប្រាស់ហិរញ្ញវត្ថុឱ្យទទួលបានលទ្ធផលល្អ ហើយគោលការណ៍នេះគេអាចហៅម៉្យាងទៀតថា **តម្លៃជាប្រាក់**.[6] ដែលជារង្វាស់នៃប្រសិទ្ធភាពដែលត្រូវបានប្តូរជាមួយ និងធនធានហិរញ្ញវត្ថុរបស់ រាជរដ្ឋាភិបាល។ មន្ត្រីលទ្ធកម្មត្រូវចងចាំថាតម្លៃជាប្រាក់រួមផ្សំ និងកត្តាមួយចំនួនទៀត មិនមែនត្រឹមតែជាកត្តា តម្លៃប៉ុណ្ណោះទេ។

កត្តាទាំងនោះរួមមាន ៖

- ភាពសមស្របនៃទំនិញ/សំណង់/សេវាកម្ម/សេវាទីប្រឹក្សា
- អាយុកាលប្រើប្រាស់នូវទំនិញ/សំណង់/សេវាកម្ម/សេវាទីប្រឹក្សា
- ចំណាយសម្រាប់ប្រតិបត្តិការ ការថែទាំ និងការផ្តល់សេវា
- ចំណាយរដ្ឋបាលក្នុងការអនុវត្តវិធីសាស្ត្រដែលបានជ្រើសរើស
- រយៈពេលប្រគល់-ទទួល
- ថ្លៃចំណាយដឹកជញ្ជូនបន្ត
- ថ្លៃចំណាយក្នុងការស្តុកទុក
- ពេលវេលាចំណាយសម្រាប់ធ្វើកិច្ចលទ្ធកម្ម។

ខ.គោលការណ៍តម្លាភាព

ភ្នាក់ងារ និងស្ថាប័នអនុវត្តលទ្ធកម្មត្រូវធានាចំពោះមុខសាធារណៈជនថា វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវដោយការធានាឱ្យបាននូវតម្លាភាពក្នុងកិច្ចលទ្ធកម្ម។ តម្លាភាពនេះនិងជំរុញលើក

[5] -មាត្រា១៣នៃអនុក្រឹត្យលេខ ១០៥ ស្តីពីលទ្ធកម្មសាធារណៈ អនក្រ.បក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០០៦

[6] -សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១០

ទឹកចិត្តដល់អ្នកផ្គត់ផ្គង់ អ្នកទទួលការឱ្យចូលរួមប្រកួតប្រជែងដើម្បីទទួលបានកិច្ចសន្យាពីរាជរដ្ឋាភិបាល ពោលគឺបង្កើតបរិយាកាសប្រកួតប្រជែង ដែលនាំឱ្យតម្លៃលក់ធ្លាក់ចុះ។

គ.គណនេយ្យភាព

មន្ត្រីលទ្ធកម្មត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ចំពោះការងារដែលរាជរដ្ឋាភិបាលបានប្រគល់ជូនក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈដើម្បីធានាឱ្យបាននូវគោលការណ៍នេះ ព្រោះថា គណនេយ្យភាពគឺជាមូលដ្ឋានគ្រឹះនៅក្នុងការអនុវត្តលទ្ធកម្មសាធារណៈ ។

ឃ.សមភាព

អ្នកផ្គត់ផ្គង់/ទទួលការ ដែលមានសិទ្ធិចូលរួមដេញថ្លៃទាំងអស់ ត្រូវទទួលបាននូវការជូនដំណឹងស្តីពីឱកាស ចូលរួមដេញថ្លៃ។ គោលការណ៍នេះមិនត្រឹមតែធានាឱ្យបាននូវសមភាពក្នុងការប្រកួតប្រជែងប៉ុណ្ណោះទេ តែថែម ទាំងធ្វើឱ្យមានយុត្តិធម៌ដល់អ្នកដេញថ្លៃថ្នាក់ជាតិ និងអន្តរជាតិ អ្នកផ្គត់ផ្គង់ អ្នកទទួលការ និងទីប្រឹក្សា ឬដៃគូរ អភិវឌ្ឍន៍ផ្សេង។ ក្នុងកម្មវត្ថុ បង្កើនជម្រើសដល់រាជរដ្ឋាភិបាល ក្នុងការវិនិច្ឆ័យថាតើក្រុមហ៊ុន ណាមួយដែលមាន លក្ខខណ្ឌសមស្របក្នុងការផ្គត់ផ្គង់ដល់តម្រូវការរបស់រដ្ឋ។

ង.ប្រសិទ្ធភាព

ការអនុវត្តកិច្ចលទ្ធកម្ម ជាការប្រមូលទិន្នន័យស្តីពីលទ្ធភាព សមត្ថភាពរបស់អ្នកផ្គត់ផ្គង់ក្នុងការបំពេញតម្រូវការក្នុងលក្ខខណ្ឌសមស្របណាមួយតាមកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាល និងអ្នកផ្គត់ផ្គង់។ ការអនុវត្តកិច្ចលទ្ធកម្ម ជាកិច្ចការមួយដើម្បីធានាឱ្យការប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព ។

ច.ក្រមសីលធម៌វិជ្ជាជីវៈ

ក្នុងកិច្ចដំណើរការលទ្ធកម្ម ភ្នាក់ងារទទួលបន្ទុកត្រូវប្រកាន់ភ្ជាប់នូវការគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដែលឆ្លើយតបទៅនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត និងអំពើបង្ខិតបង្ខំ ដល់អ្នកដេញថ្លៃដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ដែលប្រាស់ចាកពីផលប្រយោជន៍សង្គមជាតិ។

ស្ថាប័នដែលទទួលបន្ទុកលើកិច្ចការលទ្ធកម្មត្រូវរក្សា នឹងពង្រឹងកេរ្តិ៍ឈ្មោះរបស់រាជរដ្ឋាភិបាលដោយ៖

- រក្សានូវភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរ ចំពោះរាល់ទំនាក់ទំនងក្នុងស្ថាប័ន និងក្រៅស្ថាប័នរបស់ខ្លួន
- បង្កើនសមត្ថភាពវិជ្ជាជីវៈស្របតាមបទដ្ឋានខ្ពស់មួយតាមលទ្ធភាពដែលអាចធ្វើបាន
- ប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់ជាតិ

- គោរពតាមខ្លឹមសារ និងស្មារតីនៃរដ្ឋធម្មនុញ្ញច្បាប់ និងបទប្បញ្ញត្តិផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ក្រមសីលធម៌វិជ្ជាជីវៈ និងកាតព្វកិច្ចដែលបានកំណត់ក្នុងកិច្ចសន្យា
- ត្រូវប្រាស់ចាកអំពីទំនាស់ផលប្រយោជន៍ និងក្រមសីលធម៌វិជ្ជាជីវៈដូចជា ការទម្លាយការសម្ងាត់ឬព័ត៌មាន ផ្ទៃក្នុង មានភាពលំអៀង និងការស៊ើសំណូក សូកប៉ាន់។ល។

ផ្នែកទី២ វិធីសាស្ត្រលទ្ធកម្ម និងនីតិវិធីលទ្ធកម្មសាធារណៈ

១.វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម

វិធីសាស្ត្រវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម របស់រដ្ឋបាលក្រុង ស្រុក មានដូចជា ៖

១.១.វិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងជាសាធារណៈ

ក.ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ

ជាវិធីសាស្ត្រលទ្ធកម្មមួយដែលគេនិយមប្រើជាងគេដោយសារវិធីសាស្ត្រនេះផ្តល់ឱ្យអ្នកទិញ ឬស្ថាប័នអនុវត្តលទ្ធកម្មនៃការជ្រើសរើសយ៉ាងទូលំទូលាយក្នុងចំណោមអ្នកផ្គត់ផ្គង់ដែលប្រកួតប្រជែង ហើយផ្តល់ឱ្យអ្នកផ្គត់ផ្គង់នូវឱកាសគ្រប់គ្រាន់ យុត្តិធម៌ និងស្មើភាពគ្នា។ វិធីសាស្ត្រនេះចាំបាច់ត្រូវប្រើសម្រាប់គម្រោងចំណាយដែល មានទំហំទឹកប្រាក់ធំ ដែលអាចចូលរួមពីអ្នកដេញថ្លៃបរទេស និងផ្តល់លក្ខណៈបច្ចេកទេសក្នុងកម្រិតទូលំទូលាយ ដើម្បីធ្វើការជ្រើសរើសយកសំណើដេញថ្លៃដែលមានលក្ខណៈសន្សំសំចៃ និងផ្តល់អត្ថប្រយោជន៍ជាងគេ។

ការប្រកាសផ្សព្វផ្សាយត្រូវធ្វើឡើង ក្នុងសារព័ត៌មានមួយជាភាសាជាតិ និងជាភាសាបរទេសដែលបានធ្វើការចរចាយ៉ាងតិច ០២ឆ្នាំហើយត្រូវបានបើកចំហដល់ក្រុមហ៊ុនទាំងអស់ដែលចាប់អារម្មណ៍ចូលរួមផ្សព្វផ្សាយ លក់ ទទួល និងបើកសំណើដេញថ្លៃត្រូវគិតយ៉ាងតិច៦០ថ្ងៃ។ ឯកសារដេញថ្លៃមិនត្រូវលក់នៅថ្ងៃបើកសំណើ ដេញថ្លៃឡើយ។ គំរូឯកសារដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិនឹងត្រូវរៀបចំដោយនាយកដ្ឋាន លទ្ធកម្មសាធារណៈសម្រាប់អនុវត្ត។ អ្នកដេញថ្លៃដែលចូលរួមក្នុងវិធីសាស្ត្រនេះ ត្រូវមានប្រាក់កក់ធានាការដេញ ថ្លៃយ៉ាងតិច ០២ភាគរយនៃតម្លៃសរុបដាក់ដេញថ្លៃ។ នីតិវិធីលម្អិតសម្រាប់អនុវត្តវិធីសាស្ត្រនេះបានចែងក្នុងគំរូឯកសារដេញថ្លៃ។

ខ.ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក

វិធីសាស្ត្រនេះត្រូវអនុវត្តក្នុងករណីដែលក្រុមហ៊ុនក្នុងស្រុកមានលទ្ធភាពផ្គត់ផ្គង់គ្រប់គ្រាន់ ហើយទំហំទឹកប្រាក់ក្នុងគម្រោងចំណាយមានតម្លៃទាបជាងកម្រិតទឹកប្រាក់ដែលត្រូវអនុវត្តក្នុងវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងខ្ពស់ជាងកម្រិតទឹកប្រាក់ដែលត្រូវអនុវត្តនូវវិធីសាស្ត្រពិគ្រោះថ្លៃ។

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុកនេះត្រូវមានលិខិតប្រាក់កង់ធានាការដេញថ្លៃមិនតិចជាង០២ភាគរយនៃតម្លៃសរុបដាក់ដេញថ្លៃឡើយ។ ចំពោះការផ្សព្វផ្សាយត្រូវចុះផ្សព្វផ្សាយតាមសារព័ត៌មានជាភាសាជាតិដែលបានធ្វើចរាចរទូលំទូលាយក្នុងស្រុកយ៉ាងតិច ០២ឆ្នាំ។ អ្នកដេញថ្លៃគ្រប់រូបទាំងក្នុងប្រទេសនិងក្រៅប្រទេសមានសិទ្ធិចូលរួមដេញថ្លៃដោយស្មើភាពគ្នា ដោយគ្មានការផ្តល់អាទិភាពដល់អ្នកដេញថ្លៃក្នុង ស្រុកឡើយ។

ការផ្សព្វផ្សាយលក់ ទទួល និងបើកសំណើដេញថ្លៃមានរយៈពេលយ៉ាងតិច៣០ថ្ងៃ ។ ឯកសារដេញថ្លៃត្រូវលក់ ចាប់ពីថ្ងៃផ្សព្វផ្សាយឯកសារដេញថ្លៃ ហើយឯកសារដេញថ្លៃ មិនត្រូវលក់នៅថ្ងៃបើកសំណើដេញថ្លៃឡើយ។

១.២.វិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងដ៏ទៃទៀត

ក.ការដេញថ្លៃមានកម្រិត

វិធីសាស្ត្រនេះត្រូវអនុវត្តចំពោះមុខសញ្ញាលទ្ធកម្ម ដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញមិនអាចរៀបចំបច្ចេកទេសទុកជាមុនបាន មានអ្នកដេញថ្លៃតិចតួចដែលមានសមត្ថភាពអនុវត្ត និងមានកម្រិតទឹកប្រាក់ដូចមានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំពោះការដេញថ្លៃប្រភេទនេះត្រូវអញ្ជើញអ្នកដេញថ្លៃយ៉ាងតិចចំនួន៣រូប ឬអាចប្រកាសផ្សព្វផ្សាយត្រូវធ្វើឡើងតាមរយៈសារព័ត៌មានដែលបានធ្វើចរាចរទូលំទូលាយក្នុងស្រុកយ៉ាងតិច ០២ឆ្នាំ ។ ការផ្សព្វផ្សាយលក់ ទទួល និងបើកសំណើដេញថ្លៃ មានរយៈពេលយ៉ាងតិច៦០ថ្ងៃ មុនការបើកសំណើដេញ។ តាមវិធីនេះគឺតម្រូវឱ្យមានសំណើដេញថ្លៃយ៉ាងតិចចំនួន ៣ នឹងមានសុពលភាព៦០ថ្ងៃ ចាប់ពីកាលបរិច្ឆេទបើកសំណើដេញថ្លៃ ហើយត្រូវមានលិខិតប្រាក់កក់ធានាការដេញថ្លៃមិនតិចជាង ០២ភាគរយនៃតម្លៃសរុបដាក់ដេញថ្លៃ។

ខ.ការពិគ្រោះថ្លៃ

វិធីសាស្ត្រនេះតម្រូវឱ្យមានតារាងតម្លៃដាក់នៅក្នុងស្រោមសំបុត្របិទជិត និងបោះត្រាពីលើ។ អ្នកដេញថ្លៃយ៉ាងហោចណាស់ក៏មានចំនួន៣ដែរ ដែលស្ថិតក្នុងបញ្ជីជ្រើសរើសត្រូវបានទទួលលិខិតអញ្ជើញឱ្យចូលរួមពិគ្រោះថ្លៃដោយផ្ទាល់។ ការប្រកាសផ្សព្វផ្សាយ ចែកឯកសារ បើកឯកសារ មានរយៈពេលយ៉ាងតិច ១៥ថ្ងៃ ។ ហើយការបើកឯកសារពិគ្រោះថ្លៃត្រូវធ្វើឡើងជាសាធារណៈ ឯកសារពិគ្រោះថ្លៃត្រូវមានគ្រប់គ្រាន់សម្រាប់ចែក ឱ្យអ្នកដែលមានបំណងចូលរួមពិគ្រោះថ្លៃ វិធីសាស្ត្រនេះត្រូវប្រកាសផ្សព្វផ្សាយជាភាសាជាតិក្នុងសារព័ត៌មាន ដែលបានធ្វើចរាចរទូលំទូលាយហើយមានបទពិសោធន៍យ៉ាងតិច០២ឆ្នាំ។

ប្រសិនបើក្នុងរយៈពេលផ្សព្វផ្សាយនោះទទួលបានតារាងតម្លៃតិចជាង៣ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពន្យារកាលបរិច្ឆេទបើក និងផ្សព្វផ្សាយបន្ថែមដើម្បីអញ្ជើញអ្នកផ្គត់ផ្គង់ល្បីឈ្មោះដោយផ្ទាល់ឱ្យដាក់តារាងតម្លៃ។

វិធីសាស្ត្រនេះមិនតម្រូវឱ្យមានប្រាក់កក់ពិគ្រោះថ្មីទេ ប៉ុន្តែត្រូវមានលិខិតប្រកាសជំនួសឱ្យប្រាក់កក់។

ក.ការស្នងតម្លៃ

វិធីសាស្ត្រនេះ ត្រូវបានប្រើនៅពេលដែលគម្រោងចំណាយមានតម្លៃក្នុងកម្រិតទឹកប្រាក់កំណត់តិចជាងកម្រិតទឹកប្រាក់ពិគ្រោះថ្លៃ ។ វិធីសាស្ត្រនេះមិនតម្រូវឱ្យមានការប្រកាសផ្សព្វផ្សាយ និងប្រាក់កក់ធានានោះទេ។ ក្នុងករណីនេះ មន្ត្រីលទ្ធកម្មត្រូវសាកសួរក្រុមហ៊ុនល្បីឈ្មោះផ្សេងគ្នាដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន យ៉ាងហោចណាស់ឱ្យបានចំនួន ០៣ ក្រុមហ៊ុនដែរ ហើយត្រូវធានាថាតារាងតម្លៃដែលទទួលបានពីអ្នកផ្គត់ផ្គង់ផ្សេងគ្នានោះ បានដាក់ក្នុងស្រោមសំបុត្របិទជិត ហើយត្រូវកត់ត្រា តម្លៃ ឈ្មោះ និងអាសយដ្ឋាន របស់ក្រុមហ៊ុននីមួយៗ ដើម្បីជ្រើសរើសក្រុមហ៊ុនដែលដាក់តម្លៃលក់សមស្របបំផុត។

ប្រធានអង្គភាពលទ្ធកម្មត្រូវចុះហត្ថលេខាទទួលខុសត្រូវលើកំណត់ត្រានោះដែលមានការបញ្ជាក់យល់ព្រមពីប្រធាន **គបវប**[7]។ រយៈពេលសម្រាប់អ្នកស្នងតម្លៃបំពេញតារាងតម្លៃត្រូវបានកំណត់យ៉ាងតិច៣៧ថ្ងៃ ហើយ សំណើស្នងតម្លៃត្រូវមានសុពលភាពរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃបរិច្ឆេទបើកសំណើស្នងតម្លៃ។

១.៣.ទិធីសាស្ត្រលទ្ធកម្មសាធារណៈដោយឡែក

វិធិសាស្ត្រនេះត្រូវប្រើប្រាស់សម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ឬ អ្នកផ្តល់សេវាកម្ម ដោយមិនមានការដេញថ្លៃ។ វិធីសាស្ត្រនេះអាចអនុវត្តទៅបានលុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វិធីសាស្ត្រលទ្ធកម្មដោយឡែករួមមាន ការចុះកិច្ចសន្យាផ្ទាល់ ការបន្តចុះកិច្ចសន្យា ការចុះកិច្ចសន្យា ជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋ ការចុះកិច្ចសន្យាជាមួយសហគមន៍។

ក.ការចុះកិច្ចសន្យាផ្ទាល់

ការចុះកិច្ចសន្យាដោយផ្ទាល់ ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឱ្យចរចាថ្លៃនិងបច្ចេកទេសផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈណាមួយដូចខាងក្រោម ៖

- មុខសញ្ញាលទ្ធកម្មមានប្រភពតែមួយ
- សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ ដកបទពិសោធន៍ ឬអភិវឌ្ឍន៍
- ទំនិញ ឬការងារសាងសង់ ជួសជុល សេវាកម្ម ត្រូវការចាំបាច់ចំពោះស្ថានភាពជាបន្ទាន់
- មុខសញ្ញាលទ្ធកម្មដែលជាតម្រូវការចាំបាច់បន្ទាន់ មិនមានពេលគ្រប់គ្រាន់ធ្វើការដេញថ្លៃដោយប្រកួតប្រជែងបាន
- ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈប្រព្រឹត្តទៅ០២ដងរួចមកហើយត្រូវបរាជ័យ

[7] -គបវប:គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា

- ក្នុងស្ថានភាពមិនសមស្របនឹងមិនអាចជ្រើសយកវិធីសាស្ត្រការដេញថ្លៃដោយប្រកួតប្រជែងបាន។

ខ. ការបន្តចុះកិច្ចសន្យា

ជាវិធីសាស្ត្រលទ្ធកម្ម ដែលតម្រូវឱ្យចរចាថ្លៃ និងបច្ចេកទេសផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈណាមួយដូចជា មុខសញ្ញាលទ្ធកម្មដូចគ្នានឹងមុខសញ្ញាលទ្ធកម្មដើមដែលទទួលបានតាមរយៈការដេញថ្លៃ។ កិច្ចលទ្ធកម្មនោះត្រូវស្ថិតក្នុងអំឡុងពេលមិនលើសពី០៦ខែបន្ទាប់ពី កិច្ចសន្យាដើមចូលជាធរមាន និងស្ថិតក្នុងឆ្នាំថវិកាតែមួយ ក្នុងនោះលទ្ធកម្មមានតម្លៃឯកតាស្មើ ឬទាបជាងតម្លៃ ឯកតាក្នុងកិច្ចសន្យាដើម និងមានតម្លៃសរុបមិនលើសពី២៥ភាគរយនៃតម្លៃកិច្ចសន្យាដើម។

គ. ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋ

ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឱ្យចរចាថ្លៃ និងបច្ចេកទេសជាមួយអង្គភាពជំនាញរបស់ស្ថាប័នរដ្ឋដែលមានធនធាន គ្រឿងចក្រ ឧបករណ៍ សម្ភារ និងកម្លាំងគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចសន្យា ក្នុងករណីដែរបរិមាណការងារមិនអាចកំណត់បានជាមុន ការងារមានទំហំតូច ឬទីកន្លែងមិនអំណោយផល ហើយមានភូមិសាស្ត្រដាច់ស្រយាល ដែលមិនអាចទាក់ទាញក្រុមហ៊ុនឱ្យចូលរួមដេញថ្លៃ ការងារមានលក្ខណៈចាំបាច់ដែល ត្រូវធ្វើបន្ថែមដើម្បីជៀសវាងការខកខាន ដល់ការងារដែលកំពុងដំណើរការដោយ អ្នកទទួលការងកជន និងក្នុង ករណីដែលមានគ្រោះមហន្តរាយធម្មជាតិ ឬតម្រូវការបន្ទាន់ដែលត្រូវធ្វើអន្តរាគមន៍ភ្លាមៗ។

ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ត្រូវផ្តល់ការយល់ព្រម ឬមិនយល់ព្រមក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ វិធីសាស្ត្រនេះមិនតម្រូវឱ្យមានការប្រកាសផ្សព្វផ្សាយ និងលិខិតប្រាក់កក់ធានានោះទេ ប៉ុន្តែត្រូវកាត់ទុក ១០ភាគរយនៃទឹកប្រាក់ទូទាត់ក្នុងដំណាក់កាលនីមួយៗ។

ឃ. ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍

ការចុះកិច្ចសន្យាជាមួយសហគមន៍ គឺជាវិធីសាស្ត្រលទ្ធកម្មដែលត្រូវបានប្រើ សំដៅលើកទឹកចិត្តសហគមន៍ក្នុងស្រុក ដើម្បីប្រើប្រាស់កម្លាំងពលកម្ម ចំណេះដឹង និងសម្ភារក្នុងស្រុកសម្រាប់ចូលរួមក្នុងការអភិវឌ្ឍសហគមន៍។

២.វិធីសាស្ត្រលទ្ធកម្មសាធារណៈសេវាទីប្រឹក្សា

២.១.ការជ្រើសរើសដោយផ្អែកលើគុណភាព

វិធីសាស្ត្រនេះត្រូវបានគេប្រើនៅពេលដែលគុណភាព គឺជាការពិចារណាសំខាន់បំផុតនៅក្នុងដំណើរការជ្រើសរើស។ ការផ្សព្វផ្សាយអំពីតម្រូវការជ្រើសរើស ត្រូវប្រកាសទាំងនៅក្នុងស្រុក និងក្រៅស្រុក ហើយត្រូវធ្វើ

បញ្ជីជ្រើសរើសខ្លី ពីក្នុងចំណោមក្រុមហ៊ុននានាដែលមានចំណាប់អារម្មណ៍។ បន្ទាប់មកទីប្រឹក្សាទាំងអស់ត្រូវបានស្នើ សុំឱ្យដាក់សំណើបច្ចេកទេស ហើយសំណើនីមួយៗត្រូវបានចាត់លំដាប់ថ្នាក់ផ្អែកតាមពិន្ទុបច្ចេកទេស ដោយ ផ្ទៀងផ្ទាត់ជាមួយនឹងលក្ខខណ្ឌវិនិច្ឆ័យ ដែលបានចែងនៅក្នុងសំណើផ្តល់សេវាទីប្រឹក្សា។

ក្រុមហ៊ុនដែលបានពិន្ទុបច្ចេកទេសខ្ពស់បំផុត ត្រូវបានអញ្ជើញមុនគេមកចរចាប្រគល់កិច្ចសន្យា ដោយផ្អែកលើសំណើរបច្ចេកទេស និងសំណើហិរញ្ញវត្ថុ។ វិធីសាស្ត្រនេះប្រើសមស្របសម្រាប់ចំពោះតែ ៖

- សិក្សាអំពីសេដ្ឋកិច្ចក្នុងស្រុក ឬអំពីផ្នែកនានា ការសិក្សាអំពីលទ្ធភាពពហុផ្នែក ការបង្កើតរោងចក្រ ដែលកាត់បន្ថយគ្រោះថ្នាក់ ឬផែនការមេសម្រាប់អភិវឌ្ឍន៍ទីក្រុង ឬកំណែទម្រង់ផ្នែកហិរញ្ញវត្ថុ
- ការងារដែលមានផលប៉ះពាល់ខ្លាំង ហើយដែលគោលបំណងរបស់វា គឺតម្រូវឱ្យមានអ្នកជំនាញការប្រសើរបំផុត។ ឧទាហរណ៍ ដូចជាការសិក្សាអំពីលទ្ធភាព និងរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធធំៗ ការសិក្សាអំពីការគ្រប់គ្រងរបស់ក្រសួង និងស្ថាប័នធំៗរបស់រាជរដ្ឋាភិបាល។ល។
- ការងារមិនអាចប្រៀបប្រដូចគ្នាបាន ឧទាហរណ៍ ដូចជា ការសិក្សាអំពីគោលនយោបាយ។

ចំណាំ៖ តម្លៃនៃសេវាកម្ម គឺអាស្រ័យលើគុណភាពនៃការវិភាគ។

២.២. ការជ្រើសរើសដោយផ្អែកលើគុណភាព និងតម្លៃ

ក. វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព និងតម្លៃជាអន្តរជាតិ

វិធីសាស្ត្រនេះគឺជាវិធីសាស្ត្រដែលមានលក្ខណៈបទដ្ឋានលទ្ធកម្មសេវាទីប្រឹក្សា លើកលែងតែក្នុងកាលៈទេសៈ ទាំងឡាយណាដែលវិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព ត្រូវបានយកមកប្រើ និងត្រូវបានទទួលការយល់ ព្រមពីនាយកដ្ឋានលទ្ធកម្មសាធារណៈ ឬដៃគូអភិវឌ្ឍន៍។ តម្រូវការជ្រើសរើសត្រូវបានប្រកាសផ្សាយទាំងនៅក្នុង ស្រុក និងក្រៅស្រុក ហើយបញ្ជីខ្លីត្រូវបានដកស្រង់ចេញពីក្រុមហ៊ុនទាំងអស់ដែលបានដាក់សំណើ។

ក្រោយពីការវាយតម្លៃបច្ចេកទេស គុណភាពបានចប់ពេញលេញ និងបានទទួលលិខិតយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬដៃគូរអភិវឌ្ឍន៍រួចហើយ ត្រូវធ្វើការប្រជុំបើកជាសាធារណៈ ដោយត្រូវអញ្ជើញតំណាងក្រុមហ៊ុនឱ្យចូលរួម។ នៅក្នុងការប្រជុំនេះ ពិន្ទុបច្ចេកទេសរបស់ក្រុមហ៊ុនត្រូវបានប្រកាសឱ្យដឹងហើយសំណើហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក៏ត្រូវបើកមើល និងអានឱ្យខ្លាំងៗដែរ។ ក្រោយការបើកមើលសំណើហិរញ្ញវត្ថុរួចត្រូវផ្ទៀងផ្ទាត់មើលកំហុស និងត្រូវកំណត់ពិន្ទុសរុបលើសំណើបច្ចេកទេស និងសំណើហិរញ្ញវត្ថុសម្រាប់គម្រោងនីមួយៗ។ សំណើណាដែលមានពិន្ទុខ្ពស់បំផុត និងត្រូវអញ្ជើញមុនគេមកចរចាចុះកិច្ចសន្យា។ ការចរចាមិន ត្រូវគិតពីតម្លៃឯកតាដែលបានវាយតម្លៃក្នុងដំណាក់កាលជ្រើសរើសរួចហើយ។

ខ. វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព និងតម្លៃក្នុងស្រុក

វិធីសាស្ត្រនេះប្រើគ្រប់ប្រភេទលទ្ធកម្មសេវាទីប្រឹក្សាទាំងអស់ ដែលមានទឹកប្រាក់ស្ថិតក្រោមកម្រិតទឹកប្រាក់ដែលបានកំណត់ ហើយនៅពេលធ្វើតែទីប្រឹក្សាក្នុងស្រុកប៉ុណ្ណោះ។ វិធីសាស្ត្រនេះដូចគ្នាទៅនឹងវិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព និងតម្លៃជាលក្ខណៈអន្តរជាតិដែរ ខុសគ្នាតែ វិធីសាស្ត្រនេះប្រើប្រាស់គំរូឯកសារដេញថ្លៃក្នុងស្រុក ហើយការផ្សព្វផ្សាយអំពីតម្រូវការជ្រើសរើសត្រូវប្រកាសតែនៅក្នុងស្រុកប៉ុណ្ណោះ។

២.៣. វិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់

វិធីសាស្ត្រនេះប្រើសម្រាប់ការងារធម្មតាដែលបានកំណត់ថវិកា និងទិសដៅច្បាស់លាស់។ ការប្រកាសផ្សព្វផ្សាយពីតម្រូវការជ្រើសរើស ត្រូវធ្វើឡើងទាំងក្នុងស្រុក និងក្រៅស្រុក។ សំណើដេញថ្លៃត្រូវប្រាប់ឱ្យដឹងពីចំនួនថវិកាដែលមាន រួចអញ្ជើញក្រុមហ៊ុនឱ្យដាក់សំណើបច្ចេកទេសតម្រូវតាមថវិកាដែលមាននោះ។ បន្ទាប់មកសំណើបច្ចេកទេសត្រូវធ្វើការវាយតម្លៃ ដូចគ្នានឹងវិធីសាស្ត្រជ្រើសរើសផ្អែកលើលក្ខណៈសម្បត្តិ និងវិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព និងតម្លៃជាលក្ខណៈអន្តរជាតិដែរ។

ក្រោយការបញ្ចប់ការវាយតម្លៃសំណើបច្ចេកទេសរួច និងបន្ទាប់ពីគ្មានការជំទាស់ទៅនឹងរបាយការណ៍វាយតម្លៃ ត្រូវធ្វើការបើកជាសាធារណៈនូវសំណើហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានចូលរួម។ នៅពេលបើកមើលត្រូវប្រកាសឱ្យដឹងពីពិន្ទុលើបច្ចេកទេសរបស់ក្រុមហ៊ុននីមួយៗ រួចហើយទើបបើកសំណើហិរញ្ញវត្ថុ។ ក្រុមហ៊ុនដែលបានដាក់សំណើលើសពីចំនួនថវិកាដែលមាន ត្រូវបដិសេធ។ ចំណែកឯក្រុមហ៊ុនដែលបានពិន្ទុខ្ពស់បំផុតលើសំណើបច្ចេកទេស ហើយសំណើហិរញ្ញវត្ថុស្ថិតនៅក្នុងកម្រិតថវិកាដែលមាន ត្រូវបានអញ្ជើញមកធ្វើការចរចាដើម្បីចុះកិច្ចសន្យា ។

២.៤.វិធីសាស្ត្រជ្រើសរើសផ្អែកលើតម្លៃទាបបំផុត

វិធីសាស្ត្រនេះសមស្របសម្រាប់ប្រៃតែសេវាទីប្រឹក្សាដែលមានលក្ខណៈបទដ្ឋាន និងមានរៀបចំបានល្អ ដូចជាសវនកម្ម និងការងារវិស្វកម្មដែលមិនស្មុគស្មាញហើយមានការរៀបចំឡើងបានល្អ។ ការប្រកាសផ្សព្វផ្សាយអំពីតម្រូវការជ្រើសរើសត្រូវធ្វើឡើងទាំងក្នុងស្រុក និងក្រៅស្រុក និងត្រូវធ្វើបញ្ជីជម្រើសខ្លីពីក្រុមហ៊ុនដែលបានដាក់សំណើ។ សំណើដេញថ្លៃត្រូវមានកំណត់ពីពិន្ទុទាបបំផុតលើបច្ចេកទេស។

បន្ទាប់មកត្រូវបដិសេធសំណើទាំងឡាយណា ដែលមានពិន្ទុបច្ចេកទេសមិនដល់កម្រិតទាបបំផុត។ សំណើដែលមានពិន្ទុបច្ចេកទេសស្ថិតក្នុងកម្រិតទាបបំផុត ត្រូវយកមកពិនិត្យមើលសំណើហិរញ្ញវត្ថុទៀត រួចត្រូវ បើកមើលជាសាធារណៈ ហើយបន្ទាប់មកត្រូវធ្វើការចរចាប្រគល់កិច្ចសន្យា ចំពោះសំណើណាដែលបានដាក់ តម្លៃទាបបំផុត។

២.៥.វិធីសាស្ត្រជ្រើសរើសផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សា

វិធីសាស្ត្រនេះត្រូវបានគេប្រើសម្រាប់ការងារសេវាទីប្រឹក្សាតូចតាច និងងាយៗ ហើយមានទឹកប្រាក់ស្ថិតនៅក្រោមកម្រិតទឹកប្រាក់ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការប្រកាសផ្សព្វផ្សាយពីតម្រូវការជ្រើសរើសត្រូវធ្វើឡើងនៅក្នុងស្រុក (និងអាចក្រៅស្រុកលុះត្រាតែមានអ្នកជំនាញការអន្តរជាតិ) ហើយសុំឱ្យមានការបង្ហាញពីចំណាប់អារម្មណ៍ចូលរួម ដោយសូមឱ្យភ្ជាប់ព័ត៌មានលំអិតអំពីបទពិសោធន៍ និងសមត្ថភាពទាក់ទងនិងការងារដែលត្រូវផ្តល់សេវានោះ បេក្ខជនណាដែលមានលក្ខណៈសម្បត្តិប្រសើរជាងគេ នឹងត្រូវបានចរចាប្រគល់កិច្ចសន្យា។

២.៦.វិធីសាស្ត្រជ្រើសរើសលើមូលដ្ឋានប្រភពតែមួយ

វិធីសាស្ត្រនេះប្រើបានសម្រាប់តែក្នុងកាលៈទេសៈពិសេសដូចខាងក្រោមតែប៉ុណ្ណោះ ៖

- សម្រាប់ការងារបន្តពីការងារចាស់ដែលបានអនុវត្តដោយក្រុមហ៊ុនមុន
- ក្នុងករណីបន្ទាន់បំផុតដូចជាអន្តរាគមន៍ចំពោះគ្រោះធម្មជាតិតម្រូវឱ្យមានការឆ្លើយតបភ្លាមៗ
- ក្នុងករណីមានតែមួយក្រុមហ៊ុនតែប៉ុណ្ណោះដែលមានសមត្ថភាពនិងបទពិសោធន៍សម្រាប់ការងារនេះ។

២.៧.វិធីសាស្ត្រជ្រើសរើសទីប្រឹក្សា៦កត្តជន

វិធីសាស្ត្រនេះតម្រូវឱ្យមានការប្រកាសផ្សព្វផ្សាយ ព្រោះថាការប្រកាសផ្សព្វផ្សាយគឺជានីតិវិធីដែលមានប្រសិទ្ធភាពក្នុងការបង្ហាញអំពី ចំណាប់អារម្មណ៍នៃការចូលរួម ពីទីប្រឹក្សាម្នាក់ៗ សម្រាប់យកមកធ្វើការវាយតម្លៃ។ ការវាយតម្លៃក្នុងការជ្រើសរើសផ្អែកទៅលើវាយតម្លៃសមត្ថភាពទីប្រឹក្សាម្នាក់ៗ ដូចជាការអប់រំ បទពិសោធន៍ ចំណេះដឹង ភាសា វប្បធម៌ ប្រព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធរដ្ឋាភិបាល។ ទីប្រឹក្សាម្នាក់ៗដែលត្រូវបានវិនិច្ឆ័យថា មានលក្ខណៈសម្បត្តិប្រសើរជាងគេក្នុងចំណោមបេក្ខជនយ៉ាងហោចណាស់០៣នាក់ ត្រូវបានអញ្ជើញធ្វើការ ប្រគល់កិច្ចសន្យា។

៣.នីតិវិធីលទ្ធកម្មសាធារណៈលើទំនិញ សំណង់ និងសេវាកម្ម

៣.១.នីតិវិធីលទ្ធកម្មសាធារណៈសម្រាប់វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ

ក.ការកំណត់លក្ខណៈអ្នកដេញថ្លៃដែលមានសិទ្ធិដាក់សំណើដេញថ្លៃ

អ្នកដេញថ្លៃដែលមានសិទ្ធិដាក់សំណើដេញថ្លៃ គឺជាអ្នកដេញថ្លៃដែលមានឈ្មោះនៅក្នុងបញ្ជីដែលត្រូវបានរៀបចំ និងអនុម័តទទួលស្គាល់ថាមានសិទ្ធិ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្តល់ឱកាសដោយយុត្តិធម៌ និងស្មើភាពគ្នាគ្រប់អ្នកដេញថ្លៃដែលមានឈ្មោះក្នុងបញ្ជី លើកលែងតែ អ្នកដេញថ្លៃទាំងឡាយណាដែលកំពុងស្ថិតនៅក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់ដោយតុលាការ។.

ខ.ដំណាក់កាលនៃកិច្ចលទ្ធកម្មសម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ

ដំណើរការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈមានដំណាក់កាលសំខាន់ៗដូចជា ៖

១.ការរៀបចំឯកសារដេញថ្លៃ ៖ ឯកសារដេញថ្លៃត្រូវរៀបចំឱ្យស្របទៅតាម គំរូស្តង់ដារបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។[8]

២.ការផ្តល់ដំណឹងស្តីពីការដេញថ្លៃ និងការលក់ឯកសារដេញថ្លៃ ៖ ការកំណត់តម្លៃនៃឯកសារដេញថ្លៃត្រូវ ផ្អែក តាមតម្លៃផលិតជាក់ស្តែង។

ថ្លៃដូចខាងក្រោមនេះត្រូវបានយកមកប្រើធ្វើជាគោលការណ៍ ៖

ឯកសារដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក : ២០០០រ/ទំព័រ បូកថែម ២៤០០០០រ/ឯកសារ ។

ឯកសារដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ : ២០០០រ/ទំព័រ បូកថែម៦៤០០០០រ/ឯកសារ។

ដូចនេះឯកសារដេញថ្លៃក្នុងស្រុកចំនួន១០០ទំព័រ អាចនឹងលក់ក្នុងតម្លៃ៤៤០០០០រ និង ឯកសារដេញ ថ្លៃជាលក្ខណៈអន្តរជាតិ ១០០ទំព័រអាចនឹងលក់ក្នុងតម្លៃ៨៤០០០០រ។[9]

ចំពោះលទ្ធកម្មទំនិញ សំណង់ និងសេវាកម្មដែលអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជា លក្ខណៈអន្តរជាតិ រយៈពេលផ្សព្វផ្សាយលក់ និងទទួលឯកសារយ៉ាងតិច៦០ថ្ងៃ ឬច្រើនជាងនេះ ប្រសិនបើ កិច្ចការនោះមានលក្ខណៈស្មុគស្មាញខ្លាំង។ ចំពោះការកំណត់រយៈពេលចាប់ពីផ្សព្វផ្សាយរហូតដល់បើកឯកសារ សម្រាប់វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក យ៉ាងតិច៣០ថ្ងៃ ហើយ សម្រាប់វិធីសាស្ត្រពិគ្រោះថ្លៃ ចំនួន១៥ថ្ងៃ។

៣.ការទទួល និងរក្សាទុកសំណើដេញថ្លៃ៖ នៅពេលទទួលសំណើដេញថ្លៃរួច អង្គភាពលទ្ធកម្មត្រូវចេញ បង្កាន់ដៃទទួលដែលបញ្ជាក់ពីខ្លឹមសារនៃកញ្ចប់ឯកសារនោះ និងឈ្មោះអ្នកដែលបានប្រគល់។ អង្គភាពលទ្ធកម្ម ត្រូវមានភារកិច្ចទុកដាក់នៅទីតាំងដែលមានសុវត្ថិភាព ពោលគឺសំណុំឯកសារដេញថ្លៃចាំបាច់ ត្រូវរក្សាទុកក្នុង ប្រអប់ចាក់សោរ ។ ប្រធានអង្គភាពលទ្ធកម្ម ឬអ្នកទទួលសិទ្ធិម្នាក់ប៉ុណ្ណោះដែលមាន កូនសោរបើក ហើយត្រូវ មានកូនសោរបម្រុងមួយទៀតទុកនៅប្រធាន គបវប ដើម្បីបង្ការពេលបាត់កូនសោរ។

៤.ការបើកសំណើដេញថ្លៃ ៖ គណៈកម្មាធិការលទ្ធកម្មត្រូវចាប់ផ្តើមកិច្ចប្រជុំបើកសំណើដេញថ្លៃតាម ពេលវេលា និងកាលបរិច្ឆេទកំណត់។ កិច្ចប្រជុំនេះ ជាកិច្ចប្រជុំសាធារណៈ និងអាចដំណើរការទៅបាន លុះ

[8] -ប្រកាសលេខ៣២៥ សហវ. ប្រក ស្តីពីការដាក់ប្រើប្រាស់គំរូឯកសារដេញថ្លៃពិគ្រោះនិងស្នង់តម្លៃសម្រាប់ លទ្ធកម្មទំនិញនិងសំណង់ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤

[9]- សៀវភៅលទ្ធកម្មសាធារណៈនៅកម្ពុជា ស្រាវជ្រាវដោយ ឡាញ់ ដា បោះពុម្ពលើកទី១ ឆ្នាំ២០២២ ទំព័រ ៣៧

ត្រាតែ មានសមាជិកគណៈកម្មាធិការលទ្ធកម្ម ចូលរួមលើសពីពាក់កណ្តាលនៃ សមាជិកគណៈកម្មាធិការលទ្ធកម្ម។

៥.ការវាយតម្លៃសំណើដេញថ្លៃ ៖ កិច្ចប្រជុំវាយតម្លៃសំណើដេញថ្លៃអាចធ្វើទៅ បានលុះត្រាតែមានការចូលរួមពីសមាជិកគណៈកម្មាធិការលទ្ធកម្មលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងអស់។ កិច្ចប្រជុំ វាយតម្លៃសំណើដេញថ្លៃគឺជា កិច្ចប្រជុំសម្ងាត់។ សមាជិកគណៈកម្មាធិការលទ្ធកម្មទាំងអស់ ត្រូវចុះហត្ថលេខាទៅ លើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្ម មុននឹងចាប់ផ្តើមដំណើរការវាយតម្លៃសំណើដេញថ្លៃ។

គណៈកម្មាធិការលទ្ធកម្មត្រូវត្រួតពិនិត្យ និងវាយតម្លៃសំណើដេញថ្លៃម្តងមួយៗ ប្រធានគណៈកម្មាធិការអាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធនឹងមុខសញ្ញាលទ្ធកម្មចូលរួមផ្តល់យោបល់នៅក្នុងការវាយតម្លៃ ។ ការវាយតម្លៃសំណើដេញថ្លៃមាន៣ដំណាក់កាលគឺ ការពិនិត្យជាបឋម ការវាយតម្លៃបច្ចេកទេស ការវាយតម្លៃហិរញ្ញវត្ថុ ។

៦.ការពិនិត្យ និងវាយតម្លៃលើលក្ខណៈសម្បត្តិតាមក្រោយ ៖ ការពិនិត្យនេះគឺដើម្បីផ្ទៀងផ្ទាត់ទៅតម្រូវការ នៃផ្លូវច្បាប់ តម្រូវការនៃសមត្ថភាពបច្ចេកទេស និងសមត្ថភាពហិរញ្ញវត្ថុរបស់អ្នកដេញថ្លៃនាំមុខទី១។

៧. ការប្រគល់កិច្ចសន្យា ៖ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចនូវលទ្ធផលនៃការដេញថ្លៃផ្អែកតាមអនុសាសន៍របស់គណៈកម្មាធិការលទ្ធកម្ម ។ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ច សន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់ និងផ្សាយជាសារធារណៈ ព្រមទាំងទុករយៈពេល ១០ថ្ងៃធ្វើការ ដើម្បីឱ្យអ្នកដេញថ្លៃទាំងនោះជំទាស់តវ៉ានឹងលទ្ធផលនៃការដេញថ្លៃ។

៨.ការចុះកិច្ចសន្យា ៖ អភិបាលក្រុង ស្រុក ខណ្ឌ និងអ្នកដេញថ្លៃឈ្នះត្រូវចុះហត្ថលេខាលើកិច្ចសន្យា។

៩.ការអនុវត្តកិច្ចសន្យា ៖ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានកាតព្វកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា ចំណែកអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ មានកាតព្វកិច្ចអនុវត្តកិច្ចសន្យាតាមលក្ខខណ្ឌនៃកិច្ចសន្យា ។

៣.២.នីតិវិធីលទ្ធកម្មសាធារណៈសម្រាប់វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងដ៏ទៃទៀត

ការកំណត់លក្ខណៈអ្នកដេញថ្លៃដែលមានសិទ្ធិដាក់សំណើដេញថ្លៃ និងដំណាក់កាលនៃកិច្ចលទ្ធកម្មសម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងដទៃទៀត ត្រូវអនុវត្តដូចគ្នាទៅនឹងដំណាក់កាលនៃកិច្ចលទ្ធកម្មសម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈដែរ។

៣.៣.នីតិវិធីលទ្ធកម្មសាធារណៈសម្រាប់វិធីសាស្ត្រដេញថ្លៃដោយឡែក

នីតិវិធីលទ្ធកម្មសម្រាប់វិធីសាស្ត្រលទ្ធកម្មដោយឡែក មានដូចជា នីតិវិធីនៃការចុះកិច្ចសន្យាដោយផ្ទាល់

នីតិវិធីនៃការបន្តចុះកិច្ចសន្យា នីតិវិធីនៃការចុះកិច្ចជាមួយអង្គជំនាញនៃស្ថាប័នរដ្ឋ និងនីតិវិធីនៃការចុះកិច្ចសន្យាជាមួយសហគមន៍ មានចែងលម្អិតនៅក្នុង សេចក្តីណែនាំលេខ០០២ សហវ.អលក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពី វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

វិធីសាស្ត្រនេះប្រើបានសម្រាប់តែក្នុងកាលៈទេសៈពិសេសដូចខាងក្រោមតែប៉ុណ្ណោះ ៖

- សម្រាប់ការងារបន្តពីការងារចាស់ដែលបានអនុវត្តដោយក្រុមហ៊ុនមុន
- ក្នុងករណីបន្ទាន់បំផុតដូចជាអន្តរាគមន៍ចំពោះគ្រោះធម្មជាតិតម្រូវឱ្យមានការឆ្លើយតបភ្លាមៗ
- ក្នុងករណីមានតែមួយក្រុមហ៊ុនតែប៉ុណ្ណោះដែលមានសមត្ថភាពនិងបទពិសោធន៍សម្រាប់ការងារនេះ។

៤.នីតិវិធីលទ្ធកម្មសាធារណៈសេវាទីប្រឹក្សា

៤.១.ដំណើរការនៃការចុះកិច្ចសន្យា

សម្រាប់កិច្ចសន្យាទំហំធំ ដែលត្រូវបានផ្សព្វផ្សាយជាលក្ខណៈអន្តរជាតិ ត្រូវបានរៀបចំ ធ្វើការចរចាជាមួយក្រុមហ៊ុនទីប្រឹក្សា ដែលបានជ្រើសរើស រយៈពេលនៃការចរចាមានពី ០២ ទៅ ០៥ថ្ងៃ នៃថ្ងៃធ្វើការ។ រាល់ទិដ្ឋភាពនៃការចរចាត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ហេតុនៃការចរចានីមួយៗហើយត្រូវបានយល់ព្រមពីភាគីទាំងអស់។ ការចរចាត្រូវផ្តែកលើ លក្ខខណ្ឌការងារ ដែលទាក់ទិននិងក្រុមហ៊ុនទីប្រឹក្សាស្នើឡើងនានានៅក្នុងសំណើរបស់ពួកគេ។ ជាមូលដ្ឋាន ការចរចាមិនត្រូវមានការកែប្រែលក្ខខណ្ឌការងារ ផែនការការងារ វិធីសាស្ត្រ សមាសភាព ក្រុម ដូចដែលមាននៅក្នុងសំណើដើមនោះទេ។ ម្ចាស់គម្រោងមិនអាចសុំឱ្យផ្លាស់ប្តូរបុគ្គលិកណាមួយរបស់ ទីប្រឹក្សា ដោយពុំមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទេ។ នៅពេលដែលតម្លៃជាកត្តាមួយត្រូវធ្វើ ឡើងនៅក្នុងការចរចាជ្រើសរើស ហើយត្រូវកាត់បន្ថយ ឬ បង្កើនសំណើហិរញ្ញវត្ថុដើមរបស់ទីប្រឹក្សាលើសពី ១៥% ត្រូវមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នៅក្នុងករណីដែលម្ចាស់គម្រោងមានបំណងកាត់បន្ថយ ឬបង្កើនទំហំការងារដែលបានស្នើឡើងលើសពីកម្រិតកំណត់ នោះម្ចាស់គម្រោងត្រូវធ្វើលិខិតស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ទាប់ពីទទួលបានការយល់ព្រម ម្ចាស់គម្រោងត្រូវអញ្ជើញទីប្រឹក្សាមកចរចា ដោយបញ្ជាក់អំពីភាគរយដែលម្ចាស់គម្រោងមានបំណងកែប្រែទំហំនៃកិច្ចការ។ ក្នុងករណីកាត់បន្ថយមានផលប៉ះពាល់ធំដុំទៅលើផែនការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទីប្រឹក្សាឯកត្តជន សហការី និងក្រុមហ៊ុនទីប្រឹក្សាបន្ត ការអញ្ជើញមកចរចាត្រូវបានបដិសេធ។

៤.២.ការបញ្ចប់កិច្ចសន្យាទីប្រឹក្សា

ក្នុងករណីកិច្ចសន្យាមិនទាន់ចូលជាធរមាន កាលបរិច្ឆេទអនុវត្តការងារ និង កិច្ចសន្យាត្រូវបានចុះហត្ថលេខាដោយគូភាគីដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យា ភាគីណាមួយអាចប្រកាសកិច្ចសន្យាទុកជាមោឃៈ

ដោយ ជូនដំណឹងជាលាយលក្ខណ៍អក្សរមិនតិចជាង០៤សប្តាហ៍ ទៅភាគីមួយទៀត ហើយគ្មានភាគីណាមួយត្រូវបានទាមទារសំណងអ្វីពីភាគីម្ខាងទៀតទេ។

ម្ចាស់គម្រោងអាចបញ្ចប់កិច្ចសន្យានៅក្នុងកាលៈទេសៈដូចជា ៖

- ប្រសិនបើទីប្រឹក្សាខកខានមិនបានដោះស្រាយនូវការបរាជ័យក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចមានបញ្ជាក់នៅក្នុងការជូនដំណឹងអំពីការបញ្ឈប់ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹងនេះ ឬក្នុងរយៈពេលបន្ថែមដូចដែលម្ចាស់គម្រោងយល់ព្រមជាលាយលក្ខណ៍អក្សរ
- ប្រសិនបើទីប្រឹក្សាខកខានមិនអនុវត្តតាមសេចក្តីសម្រេចចុងក្រោយណាមួយ ដែលជាលទ្ធផលនៃការសម្រេចរបស់អាជ្ញាកណ្តាល
- ប្រសិនបើទីប្រឹក្សាដាក់ស្នើទៅម្ចាស់គម្រោង នូវសេចក្តីថ្លែងការណ៍ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍របស់ម្ចាស់គម្រោង ហើយម្ចាស់គម្រោងដឹងថាសេចក្តីថ្លែងការណ៍មិនពិត
- ក្នុងការវិនិច្ឆ័យរបស់ម្ចាស់គម្រោង ប្រសិនបើទីប្រឹក្សាបានប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ បង្ខិតបង្ខំ ឬឃុបឃិត ក្នុងការប្រជែងយកកិច្ចសន្យា ឬក្នុងការប្រតិបត្តកិច្ចសន្យា
- ករណីប្រធានសក្តិ ទីប្រឹក្សាពុំមានលទ្ធភាពបំពេញបានផ្នែកចម្បងនានានៃសេវាកម្មសម្រាប់រយៈពេលមិនតិចជាង៦០ថ្ងៃ
- ប្រសិនបើក្រុមហ៊ុនទីប្រឹក្សាក្ស័យធន ឬរំលាយខ្លួន ឬស្ថិតនៅក្នុងការគ្រប់គ្រងស្របច្បាប់របស់បុគ្គលផ្សេង ទោះដោយខានមិនបាន ឬដោយស្ម័គ្រចិត្តក្តី
- ទីប្រឹក្សាអាចបញ្ចប់កិច្ចសន្យា ក្រោយពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរមិនតិចជាង៣០ថ្ងៃ ទៅម្ចាស់គម្រោង បន្ទាប់ពីមានការកើតឡើងនូវហេតុការណ៍ណាមួយដូចខាងក្រោម៖
- ប្រសិនបើ ម្ចាស់គម្រោងខកខានមិនបានធ្វើការទូទាត់ចំនួនទឹកប្រាក់ណាមួយឱ្យទីប្រឹក្សានៅក្នុងរយៈពេល៤៥ថ្ងៃ បន្ទាប់ពីទទួលបានពីទីប្រឹក្សានូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ថាការទូទាត់នេះហួសពេលវេលាកំណត់
- ប្រសិនបើម្ចាស់គម្រោងបំពានធ្ងន់ធ្ងរលើ កាតព្វកិច្ចរបស់ខ្លួនទៅលើកិច្ចសន្យា ហើយមិនបានធ្វើការដោះ ស្រាយការបំពាននេះក្នុងរយៈពេល ៤៥ថ្ងៃ ឬវែងជាងនេះដូចដែលទីប្រឹក្សាអាចយល់ព្រមជាលាយលក្ខណ៍អក្សរ បន្ទាប់ពីទទួលបានការជូនដំណឹង ជាលាយលក្ខណ៍អក្សរ ពីទីប្រឹក្សាស្តីពីការបំពាន

- ករណីប្រធានសក្តិ ប្រសិនបើទីប្រឹក្សាពុំមានលទ្ធភាពបំពេញបានតាមផ្នែកចម្បងនានានៃសេវាកម្ម សម្រាប់រយៈពេលមិនតិចជាង៦០ថ្ងៃ
- ប្រសិនបើម្ចាស់គម្រោងខកខានមិនអនុវត្តតាមសេចក្តីសម្រេចចុងក្រោយណាមួយ ដែលជាលទ្ធផលនៃការសម្រេចរបស់អាជ្ញាកណ្តាល។

៤.៣. ថ្លៃឆ្នាត់នៃសេវាទីប្រឹក្សា

ការទូទាត់សម្រាប់កិច្ចសន្យាសេវាទីប្រឹក្សា ត្រូវធ្វើឡើងតាមរយៈវិក័យបត្ររបស់ទីប្រឹក្សា ដោយយោងតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យានីមួយៗ។

មន្ត្រីជំនាញត្រូវធានាឱ្យបានថា ៖

- វិក្កយបត្រស្នើសុំរបស់ទីប្រឹក្សាដែលមានលក្ខណៈត្រឹមត្រូវ ត្រូវផ្អែកលើមូលដ្ឋាន តារាងពេលវេលា តារាងលទ្ធផលការងារដែលបានដាក់ស្នើមកពិនិត្យ និងទទួលយកលទ្ធផលនៃការងារ ឬការវិនិច្ឆ័យ ផ្សេងទៀត ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យា
- ទឹកប្រាក់ទូទាត់មុនដែលបានឯកភាពគ្នាក្នុងដំណាក់កាលទូទាត់សងត្រូវបានដកចេញពីតម្លៃវិក្កយបត្រទូទាត់មុននឹងធ្វើការទូទាត់បន្ត ហើយក្នុងកាលៈទេសៈណាក៏ដោយការទូទាត់មុនត្រូវធ្វើឡើងនៅមុនពេលការទូទាត់មិនលើសពី៨០% នៃតម្លៃកិច្ចសន្យា
- ប្រាក់កក់ទុកដែលបញ្ជាក់នៅក្នុងកិច្ចសន្យាត្រូវបានដកចេញពីតម្លៃវិក័យប័ត្រទូទាត់មុននឹងការទូទាត់។
- ដាក់ស្នើការទូទាត់ទៅប្រធានស្ថាប័នអនុវត្តលទ្ធកម្មដើម្បីអនុម័ត ហើយបន្ទាប់ពីការអនុវត្ត ត្រូវបញ្ជូនឯកសារនេះទៅអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើការទូទាត់។

ជំពូកទី២

ការគ្រប់គ្រងរដ្ឋបាលដែនដី ក្រុងចា្បារមន

ជំពូកទី ២

ការគ្រប់គ្រងរដ្ឋបាលដែនដីក្រុងច្បារមន

ផ្នែកទី១ ៖ ទីតាំងភូមិសាស្ត្រ

១.ស្ថានភាពទូទៅ

ក្រុងច្បារមន មានទីតាំងស្ថិតនៅភាគខាងលិចរាជធានីភ្នំពេញ ចម្ងាយ ៤៨គីឡូម៉ែត្រ ។ដែលមានព្រំប្រទល់ខាងលិច ទល់នឹងឃុំ ធម្មតាអរ និងឃុំកាហែង របស់ស្រុកសំរោងទង ខាងកើតទល់នឹងឃុំវល្លិ៍ស របស់ស្រុកសំរោងទង ខាងជើងទល់នឹងឃុំព្នាយ និងឃុំខ្នុំក្រាំង របស់ស្រុកសំរោងទង ខាងត្បូងជាប់ឃុំស្ពុះរបស់ស្រុកសំរោងទង ។ ផ្ទៃដីសរុប ៩០.១ គីឡូម៉ែត្រក្រឡា ផ្ទៃដីស្រែ ៣០៤០.០៩ ហិចតា ដីចំការ ៣៣១ ហិចតា ក្រៅពីនេះគឺជាដីលំនៅឋាន ។

បច្ចុប្បន្នក្រុងច្បារមន គឺជាទីប្រជុំជនដ៏ធំរបស់ខេត្តកំពង់ស្ពឺ និងជាមជ្ឈមណ្ឌលសេដ្ឋកិច្ច នយោបាយ និងពាណិជ្ជកម្មរបស់ខេត្ត។ ក្រោមម្លប់នៃសុខសន្តិភាព និងការអភិវឌ្ឍជាបន្តបន្ទាប់ បានប្រែក្រុងច្បារមន ក្លាយជាសក្តានុពលដ៏សំខាន់សម្បូរទៅដោយរោងចក្រ សហគ្រាស មូលដ្ឋានសិប្បកម្ម និងសេវាកម្មជាច្រើនដែលផ្តល់ឱកាសដល់ប្រជាពលរដ្ឋនៅក្នុងខេត្ត និងពីបណ្តាខេត្តផ្សេងក្នុងការប្រកបការងារ និងប្រកបរបរផ្សេងៗ។ ជាក់ស្តែងប្រជាពលរដ្ឋខ្លះបានផ្លាស់ប្តូរមុខរបរ ពីការធ្វើស្រែចំការ មកជាអាជីវករ ពាណិជ្ជករ មន្ត្រីរាជការ និងបុគ្គលិកក្នុងវិស័យឯកជន និងមូលដ្ឋានសេវាកម្មផ្សេងៗ។

២. ចំនួនប្រជាជនបច្ចុប្បន្ន

គិតត្រឹម ខែ តុលា ឆ្នាំ២០២៣ ចំនួនប្រជាពលរដ្ឋក្រុងច្បារមន

ក្រុងច្បារមន សរុបមានចំនួន ១១,៣៩១ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ៥៥,២២៥ នាក់ ស្រី ២៦,២៨៥ នាក់។ ក្នុងនោះ ៖

- សង្កាត់ច្បារមន សរុបមានចំនួន ២,០២៤ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ១០,២១៦នាក់ ស្រី ៤,៩២៧ នាក់។
- សង្កាត់កណ្តោលដុំ សរុបមានចំនួន ១,៩០៧ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ៨,៥៨៨នាក់ ស្រី ៤,២២៦ នាក់។
- សង្កាត់រការធំ សរុបមានចំនួន ៣,៥៨៨ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ១៥,៥០៦ នាក់ ស្រី ៨,០១៥ នាក់។

- សង្កាត់សុព័រទេព សរុបមានចំនួន ១,៦៣៣ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ៧,៧៦៩ នាក់ ស្រី ៣,៩២៤ នាក់។
- សង្កាត់ស្វាយក្រវ៉ាន់ សរុបមានចំនួន ២,១៧៦ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ១០,១៣៣ នាក់ ស្រី ៥,១៩៣ នាក់។[10]

៣.ការគ្រប់គ្រងការងារសន្តិសុខសាធារណៈ:

ការគ្រប់គ្រងការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ គឺបញ្ហាចម្បងដែលធានាដល់ការវិនិយោគ ក៏ដូចជាការអភិវឌ្ឍ ក្នុងក្រុងផងដែរ ។ ប្រជាពលរដ្ឋរស់នៅក្នុងសុខសន្តិភាព និងគ្មានការភ័យខ្លាច មិនបារម្ភអំពីចោរកម្ម ទើបមាន ឱកាស និងពេលវេលា ដើម្បីស្វែងរកប្រាក់ចំណូលក្នុង ការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ សង្គមជាតិផងដែរ។

ក្រុងបានកំណត់ជាអាទិភាពនូវសកម្មភាពមួយចំនួន ដើម្បីពង្រឹងផ្នែកសន្តិសុខនេះ ដូចជាអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់ នៃគ្រឿងញៀន ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ វេទិកានគរបាលជួបជាមួយសហគមន៍ បានប្រជុំណែនាំជាប្រចាំដល់គណៈបញ្ជាការឯកភាពក្រុង ក្នុងការងារសន្តិសុខក្នុងមូលដ្ឋាន ដូចជាការទប់ស្កាត់កុំឱ្យមានការប្រព្រឹត្តល្បែងស៊ីសងគ្រប់ប្រភេទ ការភ្នាល់មាន់តាមកញ្ចក់ទូរទស្សន៍ជាដើម ។ រដ្ឋបាលក្រុងបានអនុវត្តបានយ៉ាងសកម្មនៅលើគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដោយផ្តោតលើលក្ខណៈសម្បត្តិ ០៩យ៉ាងគឺ ៖

- គ្មានសកម្មភាពលួច ប្លន់គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអានាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងការឆ្លើយតបគ្រោះមហន្តរាយ
- គ្មានការត្រួតពិនិត្យខុសច្បាប់។

[10] - https://km.m.wikipedia.org/wiki/ក្រុងច្បារមន

ផ្នែកទី២ ៖ រចនាសម្ព័ន្ធគ្រប់គ្រង

១.រចនាសម្ព័ន្ធរដ្ឋបាលក្រុង និងសមាសភាពដឹកនាំ

១.១.រចនាសម្ព័ន្ធរដ្ឋបាលក្រុង

រចនាសម្ព័ន្ធរដ្ឋបាលក្រុង បានកំណត់ឱ្យមានការិយាល័យចំណុះចំនួន១២ និងអង្គភាពចំណុះចំនួន១ ដូចខាងក្រោម ៖[11]

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រសង្កាត់
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

ការិយាល័យ និងអង្គភាពនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយ(០១) រូប និងមានអនុប្រធានយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ។ ប្រធានការិយាល័យមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការដើមខ្សែ (ក្របខ័ណ្ឌ ខ២) និងត្រូវតែងតាំងដោយដីការបស់រដ្ឋបាលក្រុងក្រោយមានការអនុម័តពីក្រុមប្រឹក្សា។

អនុប្រធានការិយាល័យមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការ (ក្របខ័ណ្ឌ ខ៣) និងត្រូវតែងតាំងដោយដីកា របស់រដ្ឋបាលក្រុងដោយពុំចាំបាច់មានការអនុម័តពីក្រុមប្រឹក្សាឡើយ។

[11] - យោងអនុក្រឹត្យលេខ១៨២ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធ

ដោយឡែកចំពោះប្រធានការិយាល័យ រដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធានអង្គភាពលទ្ធកម្ម មុនចេញដីកាតែងតាំង ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[12]



១.២.សមាសភាពដឹកនាំក្រុង

ក្រុងច្បារមន មាន គណៈអភិបាលចំនួនមានមួយរូប និង អភិបាលរងមានចំនួន ០៦រូបគឺ លោក ទឹម ជានូ ជាអភិបាល ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

អភិបាលរងមានចំនួន ០៦រូបគឺ ៖

1. លោក ជាត សុផល
2. លោកស្រី បែន សុខុម
3. លោក ប៊ិន ថាវរៈ
4. លោក លន់ ចិន្តា
5. លោក អ៊ុង រដ្ឋា
6. លោក រឿន ធីតា។[13]

[12] -សៀវភៅណែនាំស្តីពី ការគ្រប់គ្រងកិច្ចការរដ្ឋបាលក្រុង ស្រុក ចេញដោយ ក្រសួងមហាផ្ទៃ ឆ្នាំ២០២៣

[13] - https://km.m.wikipedia.org/wiki/ក្រុងច្បារមន

២.សមាសភាពនៃគណៈអភិបាល

២.១ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាត្រូវបានជ្រើសរើសឡើងតាមរយៈ ការបោះឆ្នោតអសាកលដែលមាន អាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ។

សមាជិកក្រុមប្រឹក្សាមានចំនួនចាប់ពី១១រូប រហូតដល់២១រូប។ ក្រុមប្រឹក្សាមានប្រធាន០១រូបដែលជាបេក្ខជនឈរឈ្មោះលេខរៀងទី០១ លើបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលទទួលបានសម្លេងគាំទ្រ ច្រើនជាងគេ។

ក្រុមប្រឹក្សា គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២.២.តួនាទីភារកិច្ចក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ តួនាទី ភារកិច្ចសំខាន់ៗដូចជា៖

ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សា ៖ ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងតិចចំនួន ១២ដង ក្នុងមួយឆ្នាំ ទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាអាចប្រជុំសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់។

ការងាររៀបចំបទបញ្ជាផ្ទៃក្នុង ៖ ក្រោយប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សាត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងតាមទម្រង់ជាដីកា និងត្រូវអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុនថ្ងៃ ២៥ថ្ងៃ ឬលើស៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី០១។

ការងាររៀបចំវិធានការគ្រប់គ្រងផ្ទៃក្នុង ៖ ក្រុមប្រឹក្សានៃអណត្តិនីមួយៗត្រូវរៀបចំ និងអនុម័តដីកាស្តីពីវិធាន គ្រប់គ្រងផ្ទៃក្នុង ដើម្បីធានានូវការលើកម្ពស់ការគ្រង់រដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

ការងារដាក់ចេញដីកា និងសេចក្តីសម្រេច ៖ ក្រុមប្រឹក្សាអាចដាក់ចេញដីកា ដើម្បីកំណត់ ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាព នីតិវិធី ឬកិច្ចការណាដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនធានរបស់ខ្លួនដោយផ្អែកតាមត្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដែលជាតម្រូវការក្នុងមូលដ្ឋាន។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាក៏អាចដាក់ចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាពីរប្រភេទគឺ សេចក្តីសម្រេចជា

លាយលក្ខណ៍អក្សរ និង/ឬ ដោយផ្ទាល់មាត់ក្នុងអង្គប្រជុំក្រុមប្រឹក្សាដោយត្រូវកត់នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សា។

ការងាររៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ៖ ក្រុមប្រឹក្សាត្រូវធ្វើការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខ្លួន ក្នុងអំឡុង ខែមិថុនា នៃឆ្នាំនីមួយៗ ដែលត្រូវធ្វើឡើងនៅតាមឃុំ សង្កាត់នានានៅក្នុងស្រុក ក្នុងគោលបំណងផ្តល់ឱកាសឱ្យក្រុមប្រឹក្សាដើម្បី៖

- **ផ្តល់ព័ត៌មាន**: ក្រុមប្រឹក្សារាយការណ៍អំពីសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និងបង្ហាញពី ផែនការសម្រាប់ឆ្នាំខាងមុខបន្ទាប់
- **ផ្តល់ប្រឹក្សា** : អ្នកចូលរួមពិភាក្សាអំពីលទ្ធផល ផ្តលព័ត៌មានត្រឡប់ទៅប្រឹក្សាអំពីការងារនៅក្នុងឆ្នាំកន្លងមក និងលើកសំណើសម្រាប់ឆ្នាំបន្ទាប់
- **ជម្រុញឱ្យមានការចូលរួម** : អ្នកចូលរួមអាចរួមចំណែកនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែល ក្នុងនោះ សំណើ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានលើយកមកពិចារណានៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា
- **លើកកម្ពស់ការសហការ** : ក្រុមប្រឹក្សាទទួលព័ត៌មានប្រសើរជាងមុន អំពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។ វេទិកាក្រុមប្រឹក្សាជំរុញ និងលើកកម្ពស់ការសហការគ្នារវាង ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។ វេទិកា ចូលរួមចំណែកក្នុងការបង្កើតនូវដំណោះស្រាយ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ។

ការងារផែនការអភិវឌ្ឍប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ៖ ក្រោយប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ យ៉ាងយូរត្រឹមឆ្នាំទី០២ នៃអាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងកិច្ចការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលមានគោលដៅ សូចនាករជាក់លាក់ និងយុត្តិសាស្ត្រដែលជាមូលដ្ឋានសម្រាប់ធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន និងសក្តានុពលនានា នៅក្នុងស្រុក ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន សំដៅឆ្លើយតបតាមតម្រូវការ។

ជំពូកទី៣

ការអនុវត្តលទ្ធកម្មសាធារណៈ ក្រុងច្បារមន ឆ្នាំងបញ្ហាប្រឈម

ជំពូកទី៣

ការអនុវត្តលទ្ធកម្មសាធារណៈក្រុងច្បារមន និងបញ្ហាប្រឈម

ផ្នែកទី១ ការរៀបចំ និងការអនុវត្តផែនការលទ្ធកម្មសាធារណៈ

១.គណៈកម្មាធិការលទ្ធកម្មសាធារណៈរបស់ថ្នាក់ក្រុង

គណៈកម្មាធិការលទ្ធកម្មរបស់ក្រុងត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ដែលមានសមាសភាពនៃគណៈកម្មាធិការលទ្ធកម្មសាធារណៈដូចខាងក្រោម ៖

- អភិបាលនៃគណៈអភិបាលក្រុង ជាប្រធាន
- អភិបាលរងនៃគណៈអភិបាលក្រុង ជាអនុប្រធាន
- សមាជិកក្រុមប្រឹក្សាក្រុង ជាសមាជិក
- សមាជិកក្រុមប្រឹក្សាក្រុង ជាសមាជិក
- នាយករដ្ឋបាលក្រុង ជាសមាជិក
- អនុប្រធានការិរដ្ឋបាល ហិរញ្ញវត្ថុក្រុង ជាសមាជិក
- ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការ ។[14]

២.អង្គភាពលទ្ធកម្មសាធារណៈ

ក្រុមប្រឹក្សាក្រុងច្បារមនបានប្រជុំសម្រេច តែងតាំង លោក **ចាន់ រតនៈ**ជាប្រធានអង្គភាពលទ្ធកម្ម និងមានតួនាទី ភារកិច្ចស្របតាមបទបញ្ញត្តិចែងជាធរមានដូចជា៖[15]

- ការរៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗផ្អែកតាមគំរូឯកសារដេញថ្លៃ ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំនិងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីកិច្ចលទ្ធកម្មនីមួយៗ លក់ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម ទទួលសំណើដេញថ្លៃនិងបកស្រាយបំភ្លឺក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ

---

[14]- សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការលទ្ធកម្ម របស់ក្រុងច្បារមន

[15] -ប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រង់ប្រការ ១៣ និង ១៥ ស្តីពីការតែងតាំងប្រធាន អនុប្រធាន និង ជំនួយការនៃអង្គភាពលទ្ធកម្ម

- រៀបចំទុកដាក់សំណើដេញថ្លៃដែលបានទទួលឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព នឹងត្រូវគ្រប់គ្រងឯកសារ ឬ លិខិតស្នាមពាក់ព័ន្ធទាំងអស់មុនបើកសំណើដេញថ្លៃ
- ចាត់ចែងរៀបចំទីកន្លែងសំរាប់បើកសំណើដេញថ្លៃ រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ ដោយការដឹកនាំត្រួតពិនិត្យដោយគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ រៀបចំរបាយការណ៍ ឬ កំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ ជួយសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ ផ្ញើលិខិតជូនដំណឹងស្តីពី ការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- រៀបចំសេចក្តីព្រាងកិច្ចសន្យាឱ្យបានសមស្របតាមបទដ្ឋានឯកសារកិច្ចសន្យា ដែលបានកំណត់ ហើយធ្វើការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ រួមធ្វើការតាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត និងរៀបចំរបាយការណ៍ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

៣.ការរៀបចំផែនការលទ្ធកម្ម

ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ គឺអាស្រ័យទៅលើកញ្ចប់ថវិការបស់រដ្ឋបាលក្រុងច្បារមន ក្នុងការវិភាជន៍ធនធានសម្រាប់គម្រោងអភិវឌ្ឍន៍ និងការវិនិយោគនានានៅក្នុងមូលដ្ឋាន។ ជាក់ស្តែង ក្រុង ស្រុក ខណ្ឌ តាមបញ្ញត្តិច្បាប់ត្រូវផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួនយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី០១ ខែធ្នូ ដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័តឱ្យបានមុខថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកាជាកំហិត។

- ត្រូវផ្អែកតាមផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលស្រុក ដើម្បីជាមូលដ្ឋាន សម្រាប់កសាងផែនការលទ្ធកម្មប្រចាំឆ្នាំ
- ត្រូវប្រមូលផ្តុំនូវតម្រូវ ឬគម្រោងនានាដែលឆ្លុះបញ្ចាំងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ទាំងទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា
- ត្រូវសិក្សាអំពីតម្រូវការលក្ខណៈបច្ចេកទេសនៃទំនិញ សំណង់ សេវាកម្ម និងលក្ខខណ្ឌការងារ និងកត្តាចាំបាច់នានានៃមុខសញ្ញាលទ្ធកម្មនីមួយៗ ដែលជាផ្នែកសំខាន់នៃឯកសារដេញថ្លៃ ដើម្បីទាក់ទាញនូវការប្រកួតប្រជែងឱ្យបានទូលំទូលាយ
- ត្រូវប្រមូលផ្តុំនូវតម្រូវការទំនិញ សំណង់ សេវាកម្ម សេវាទីប្រឹក្សា ដែលស្ថិតនៅក្នុងប្រភេទដូចគ្នា និងមានលក្ខណៈបច្ចេកទេសដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឱ្យការងារតែមួយ ឬប្រើប្រាស់ក្នុងពេល តែមួយ

ជាឡូត៍លទ្ធកម្ម.[16]

- ត្រូវផ្អែកលើតម្លៃទីផ្សារដើម្បីប៉ាន់ស្មានតម្លៃឯកតា តម្លៃសរុប និងតម្លៃសរុបរួមនៃមុខសញ្ញាលទ្ធកម្ម ឬមួយកញ្ចប់លទ្ធកម្ម ឬមួយគម្រោង ដែលត្រូវធ្វើកិច្ចលទ្ធកម្មមួយលើកៗ
- ត្រូវកំណត់វិធីសាស្ត្រលទ្ធកម្មផ្អែកទៅលើតម្លៃសរុប និងលក្ខណៈបច្ចេកទេសស្មុគស្មាញនៃគម្រោង ឬមុខសញ្ញាលទ្ធកម្មនីមួយៗ
- ត្រូវរិភាគកំណត់រយៈពេលនូវដំណាក់កាលនីមួយ នៃកិច្ចដំណើរលទ្ធកម្ម ដែលទាក់ទង និងគម្រោងនីមួយៗ។

ជាក់ស្តែងនៅក្នុងអាណត្តិទី៦(ឆ្នាំ២០១៨ - ២០២១) អង្គភាពរដ្ឋបាលក្រុងច្បារមនបាន រៀបចំដាក់សំណើលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាប្រចាំឆ្នាំ ២០១៨- ២០២១ ព្រមទាំងលក្ខណៈបច្ចេកទេស និងលក្ខខណ្ឌ យោងដាក់ជូនគណៈកម្មាធិការលទ្ធកម្មក្រុង ទៅលើគម្រោងលទ្ធកម្មចំនួន ២៤ គម្រោង ដែលបានបែងចែកជា ០៣ ប្រភេទលទ្ធកម្ម និងផែនការកែរតម្រូវ ដែលមានទំហំទឹកប្រាក់ សរុបចំនួន ២,៤៥៤.២៤៥.000 រៀល ។នៅពេលអង្គ ភាពលទ្ធកម្មទទួលបានសំណើនោះហើយ អង្គភាពលទ្ធកម្មក្រុងនិងធ្វើការបូកសរុបសំណើលទ្ធកម្មនានា ដែលទទួលបាន ដើម្បីធ្វើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំរួមទាំងសេចក្តីព្រាងផែនការនៃការកែតម្រូវក្នុង ករណីចាំបាច់ដើម្បីដាក់ជូនគណៈកម្មាធិការលទ្ធកម្មពិនិត្យ និងផ្តល់យោបល់។ ក្រោយទទួលបានផែនការ លទ្ធកម្មពីអង្គភាពលទ្ធកម្មដែលជាសេនាធិការរបស់ខ្លួនរួចមក គណៈកម្មាធិការលទ្ធកម្មត្រូវពិនិត្យ និងផ្តល់ យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មមុននិងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាព។

នៅពេលពិនិត្យចប់សព្វគ្រប់ គណៈកម្មាធិការលទ្ធកម្ម ប្រគល់ជូនសេចក្តីព្រាងផែនការលទ្ធកម្ម ឱ្យទៅក្រុមប្រឹក្សាប្រជុំពិនិត្យ និងឯកភាពលើសេចក្តីព្រាងផែនការលទ្ធកម្មនោះ។ បន្ទាប់ពីទទួលបានការឯកភាព ពីសំណាក់ក្រុមប្រឹក្សារួច ហើយ សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំនោះត្រូវបានដាក់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ពិនិត្យ និងអនុម័ត។ រយៈពេលនៃការពិនិត្យ និងអនុម័តលើគម្រោងផែនការលទ្ធកម្មពីថ្នាក់ក្រុង គឺមានរយៈពេលយ៉ាងយូរប្រាំ (០៥)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីព្រាងផែនការលទ្ធកម្ម។

[16] -ឡូត៍លទ្ធកម្ម: គឺជាការប្រមូលផ្តុំទំនិញ ឬសំណង់ដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬស្រដៀងគ្នាដាក់ ចូលក្នុងក្រុមតែមួយសម្រាប់ធ្វើលទ្ធកម្មតែមួយលើក។

៤.ផែនការលទ្ធកម្មសាធារណៈអណត្តិទី៦ និងការអនុវត្ត

៤.១.គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០១៨

ផែនការលទ្ធកម្មនៅក្នុងឆ្នាំ២០១៨នៅក្រុងច្បារមន បានលើកគ្រោងផែនការលទ្ធកម្មទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន០៦គម្រោង ដែលបែងចែកជា ០៣ប្រភេទនៃកិច្ចលទ្ធកម្មដែលក្នុងនោះមាន កិច្ចលលទ្ធកម្ម ទំនិញ កិច្ចលទ្ធកម្មសំណង់ និងកិច្ចលទ្ធកម្មសេវាកម្ម។

- **ចំពោះកិច្ចលទ្ធកម្មទំនិញ**

១.ការផ្គត់ផ្គង់ប្រេងឥន្ធនៈ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១៤.៨៧៥.០០០រៀល។

២.ការផ្គត់ផ្គង់សម្ភារការិយាល័យ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ៨.០០០.០០០រៀល។

៣.ការផ្គត់ផ្គង់សម្ភារសង្ហារឹម ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១២.០០០.០០០រៀល។

- **ចំពោះលទ្ធកម្មសំណង់**

៤.គម្រោងជួសជុលផ្លូវបេតុង១ខ្សែ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២៤.២៧០.០០០រៀល។

៥.គម្រោងជួសជុលប្រព័ន្ធលូ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ៩៩.៩៩០.០០០រៀល។

- **ចំពោះលទ្ធកម្មសេវាកម្ម**

៦.ការរៀបចំអនាម័យ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២៨៥.០០០.០០០រៀល។

៤.២.គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០១៩

ផែនការលទ្ធកម្មនៅក្នុងឆ្នាំ២០១៩នៅក្រុងច្បារមន បានលើកគ្រោងផែនការលទ្ធកម្មទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន០៦គម្រោង ដែលបែងចែកជា ២ប្រភេទនៃកិច្ចលទ្ធកម្មដែលក្នុងនោះមាន កិច្ចលលទ្ធកម្ម ទំនិញ កិច្ចលទ្ធកម្មសំណង់ និងផែនការកែរតម្រូវ ០១ ។

- **ចំពោះកិច្ចលទ្ធកម្មទំនិញ**

១.ការផ្គត់ផ្គង់ប្រេងរំអិល ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១៧.០០០.០០០រៀល។

២.ការផ្គត់ផ្គង់សម្ភារការិយាល័យ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១០.០០០.០០០រៀល។

៣.ការផ្គត់ផ្គង់សម្ភារសង្ហារឹម ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១៨.០០០.០០០រៀល។

- **ចំពោះលទ្ធកម្មសំណង់**

  គម្រោងជួសជុលផ្លូវបេតុងចំនួន ០២ខ្សែ

៤.ខ្សែទី០១ ស្ថិតនៅភូមិពាណិជ្ជកម្ម សង្កាត់ច្បារមន ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២៦៨.០០០.០០០រៀល។

៥.ខ្សែទី០២ ស្ថិតនៅភូមិហ៊ូរីកម្មករ សង្កាត់រកាធំ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ៣០.០០០.០០០រៀល។

- **ចំពោះផែនការកែតម្រូវ**

៦. គម្រោងសេវាអនាម័យបរិស្ថាន ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២៨១.០០០.០០០រៀល។

៤.៣.គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២០

ផែនការលទ្ធកម្មនៅក្នុងឆ្នាំ២០២០ នៅក្រុងច្បារមន បានលើកគ្រោងផែនការលទ្ធកម្មទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន០៦គម្រោង ដែលបែងចែកជា ៣ប្រភេទនៃកិច្ចលទ្ធកម្មដែលក្នុងនោះមាន កិច្ចលទ្ធកម្មទំនិញ កិច្ចលទ្ធកម្មសំណង់ និងកិច្ចលទ្ធកម្មសេវាកម្ម។

- **ចំពោះកិច្ចលទ្ធកម្មទំនិញ**

១.ការផ្គត់ផ្គង់ប្រេងឥន្ធនៈ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២០.០០០.០០០រៀល។

២.ការផ្គត់ផ្គង់សម្ភារការិយាល័យ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១០.០០០.០០០រៀល។

៣.ការផ្គត់ផ្គង់សម្ភារសង្ហារឹម ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១៨.០០០.០០០រៀល។

- **ចំពោះលទ្ធកម្មសំណង់**

គម្រោងជួសជុលផ្លូវបេតុង២ខ្សែ ដែលស្ថិតនៅភូមិចំការដូង

៤.ខ្សែទី០១ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ៣៣៧.០៦០.០០០រៀល។

៥.ខ្សែទី០២ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ៥១.០០០.០០០រៀល

- **ចំពោះលទ្ធកម្មសេវាកម្ម**

៦.ការរៀបចំអនាម័យ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២៦៥.០០០.០០០រៀល។

៤.៤.គម្រោងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១

ផែនការលទ្ធកម្មនៅក្នុងឆ្នាំ២០២១នៅក្រុងច្បារមន បានលើកគ្រោងផែនការលទ្ធកម្មទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន០៦គម្រោង ដែលបែងចែកជា ៣ប្រភេទនៃកិច្ចលទ្ធកម្មដែលក្នុងនោះមាន កិច្ចលលទ្ធកម្មទំនិញ កិច្ចលទ្ធកម្មសំណង់ និងកិច្ចលទ្ធកម្មសេវាកម្ម។

- **ចំពោះកិច្ចលទ្ធកម្មទំនិញ**

១.ការផ្គត់ផ្គង់ប្រេងឥន្ធនៈ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២០.០០០.០០០រៀល។

២.ការផ្គត់ផ្គង់សម្ភារការិយាល័យ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២៨.៩៩០.០០០រៀល។

៣.ការផ្គត់ផ្គង់សម្ភារសង្ហារឹម ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ១៨.០០០.០០០រៀល។

- **ចំពោះលទ្ធកម្មសំណង់**

គម្រោងជួសជុលផ្លូវបេតុងចំនួន២ខ្សែ

៤.ខ្សែទី០១ស្ថិតនៅភូមិស្នោទី០១សង្កាត់រកាធំ មានតម្លៃគម្រោងសរុបជាទឹកប្រាក់៣០០.០៦០.០០០រៀល។

៥.ខ្សែទី០២ ស្ថិតនៅភូមិស្នោទី០២ សង្កាត់សុព័រទេព ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ៤៣.០០០.០០០រៀល។

- **ចំពោះលទ្ធកម្មសេវាកម្ម**

៦.ការរៀបចំអនាម័យ ដែលមានតម្លៃគម្រោងសរុបជាទឹកប្រាក់ ២៧៥.០០០.០០០រៀល។[17]

៤.៥.ការអនុវត្តផែនការលទ្ធកម្មសាធារណៈក្រុង

បន្ទាប់ពីគម្រោងផែនការលទ្ធកម្មដែលបានត្រួតពិនិត្យ ដោយក្រុមប្រឹក្សាហើយបានអនុម័តយល់ព្រមពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ស្ពឺរួចមក។ គណៈកម្មាធិការលទ្ធកម្ម ដែលមានអង្គភាពលទ្ធកម្មជាសេនាធិការក្នុងការអនុវត្តសកម្មភាពទៅតាមទម្រង់បែបបទ និងគោលការណ៍ជាធរមានទៀតនោះ បានធ្វើឱ្យសកម្មភាពលទ្ធកម្មនៅក្រុងច្បារមនក្នុងអាណត្តិទី៦ (២០១៨-២០២១)បានសម្រេចយ៉ាងជោគជ័យទៅតាមផែនការដែលបានគ្រោងទុក ដោយឆ្លើយតបបានតាមគោលការណ៍សន្សំសំចៃ និងប្រកបដោយស្តង់ដារគុណភាពខ្ពស់។

៤.៦.លទ្ធផលនៃការអនុវត្តកិច្চលទ្ធកម្មសាធារណៈ

បើយោងតាមប្រសាសន៍របស់លោក ប្រធានអង្គភាពលទ្ធកម្មក្រុងច្បារមន បានមានប្រសាសន៍ថាក្រុមហ៊ុនដែលទទួលបានការប្រគល់កិច្ចសន្យាពីសំណាក់គណៈកម្មាធិការលទ្ធកម្ម គឺបានអនុវត្តន៍ទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា និង ឆ្លើយតបតាមតម្រូវការ និងស្តង់ដាគុណភាពដែលបានកំណត់ទុក ដែលធានាដល់ភាពយូរអង្វែងនៃការប្រើប្រាស់។[18]

ជាក់ស្តែងនៅក្នុងអាណត្តិទី០៦ គ្រប់គម្រោងទាំងអស់ដែលបានអនុម័តឱ្យធ្វើលទ្ធកម្មសាធារណៈគឺបានអនុវត្តន៍ប្រកបដោយជោគជ័យទៅលើគ្រប់គម្រោងទាំង ២៣ គម្រោង និង ០១ គម្រោងផែនការកែរតម្រូវដែលមាននៅក្នុងផែនការនៃកិច្ចលទ្ធកម្ម។

ការអនុវត្តកិច្ចលទ្ធកម្មអាណត្តិទី៦របស់ក្រុងច្បារមនទទួលបានវិឌ្ឍនភាពសម្រេចតាមផែនការលទ្ធកម្មប្រចាំឆ្នាំនៃការអនុវត្តកិច្ចលទ្ធកម្មទទួលបានសមិទ្ធផលដូចខាងក្រោម៖

១. ការផ្តត់ផ្តង់ប្រេងឥន្ធនៈ ដែលមានទំហំទឹកប្រាក់សរុប ៥៤.៨៧៥.០០០ រៀល។

[17] -ឯកសារចម្លងដោយដៃចេញពីរបាយការណ៍គម្រោងលទ្ធកម្មសាធារណៈរបស់អង្គភាពលទ្ធកម្ម ក្រុងច្បារមន

[18] -កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោកប្រធានអង្គភាពលទ្ធភាពក្រុងច្បារមន (ដោយនិស្សិតខេង វ៉ែងហួរ និងទូច លៀងហួរ)

២. ការផ្គត់ផ្គង់ប្រេងរំអិល ដែលមានទំហំទឹកប្រាក់សរុប ១៧.000.000 រៀល។

៣. ការផ្គត់ផ្គង់សម្ភារការិយាល័យ ដែលមានទំហំទឹកប្រាក់សរុប ៥៦.៩៩0.000 រៀល។

៤. ការផ្គត់ផ្គង់សម្ភារសង្ហារឹម ដែលមានទំហំទឹកប្រាក់សរុប ៦៦.000.000 រៀល។

៥. គម្រោងជួសជុលផ្លូវបេតុងចំនួន0៧ខ្សែ ដែលមានទំហំទឹកប្រាក់សរុប ១.0៥៣.៣៩0.000រៀល។

៦. គម្រោងជួសជុលប្រព័ន្ធលូ ដែលមានទំហំទឹកប្រាក់សរុប ៩៩.៩៩0.000 រៀល។

៧. ការរៀបចំអនាម័យ ដែលមានទំហំទឹកប្រាក់សរុប ៨២៥.000.000 រៀល។

៨. ផែនការកែរតម្រូវ គម្រោងសេវាអនាម័យបរិស្ថាន ដែលមានទំហំទឹកប្រាក់សរុប ២៨១.000.000 រៀល ។

៥.នីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មសាធារណៈ

តាមប្រសាសន៍លោកប្រធានអង្គភាពលទ្ធកម្មក្រុងច្បារមនបាន បង្ហាញអំពីវឌ្ឍនភាពនៃការ សម្រេចបាននូវលទ្ធផលជាទីគាប់ប្រសើរលើការអនុវត្តផែនការលទ្ធកម្មក្នុងអាណត្តិទី0៦ (២0១៨-២0២១)កន្លងទៅ។ លោក បានបន្ថែមទៀតថា ការអនុវត្តលទ្ធកម្មសាធារណៈក្នុងអាណត្តិទី0៦(២0១៨-២0២១)គឺអង្គភាពលទ្ធកម្ម ក្រុងពុំទទួលបាន ពាក្យបណ្តឹងឬវិវាទណាមួយពីសំណាក់ភាគីដែលមានការពាក់ព័ន្ធក្នុងកិច្ចអនុវត្តលទ្ធកម្មទាំងនេះ។ ផ្ទុយទៅវិញ សមិទ្ធផលដែលបានមកពីការអនុវត្តកិច្ចលទ្ធកម្មទាំងនោះគឺ ទទួលបានការកោតសរសើរពីសំណាក់ស្ថាប័នគ្រប់គ្រងកិច្ចលទ្ធកម្មនិងកាន់តែទទួលបានទំនុកចិត្តពីសំណាក់សាធារណៈជនជុំវិញ សកម្មភាពនៃការប្រើប្រាស់ថវិកាជាតិរបស់រដ្ឋបាលក្រុងច្បារមនបន្ថែមទៀតផងដែរ។[19]

៥.១.នីតិវិធីនៃការប្តឹងតវ៉ាលទ្ធកម្មសាធារណៈ

គ្រប់ពេលបើទោះបីជាមាន ឬគ្មានដំណោះស្រាយ អ្នកដេញថ្លៃ និងទីប្រឹក្សាអាចដាក់បណ្តឹងតវ៉ាស្តីពីដំណើរការលទ្ធកម្មបាន នៅពេលដែលកិច្ចសន្យាមានចែងពីយន្តការដោះស្រាយបណ្តឹងតវ៉ា រួមទាំងការដោះស្រាយវិវាទតាមរយៈតុលាការ។ ភាគីទាំងអស់ត្រូវអនុវត្តតាមយន្តការផ្លូវការណាដែលឆ្លើយតបសមស្របទៅនឹងបណ្តឹងតវ៉ា។ នីតិវិធីបណ្តឹងតវ៉ាត្រូវភ្ជាប់ជាមួយលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា។ អ្នកដេញថ្លៃ ឬទីប្រឹក្សាមានសិទ្ធិប្តឹងតវ៉ាចំពោះដំណាក់កាលណាមួយនៃដំណើរការលទ្ធកម្មជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាលើពាក្យបណ្តឹងនោះ។ ពាក្យបណ្តឹងតវ៉ាត្រូវផ្ញើជូនស្ថាប័នអនុវត្តលទ្ធកម្ម ដោយបញ្ជាក់ពីឈ្មោះ មុខតំណែង និងអាសយដ្ឋានមន្ត្រីដែលទទួលខុសត្រូវក្នុងស្ថាប័ននោះ។ ស្ថាប័នអនុវត្តលទ្ធកម្ម និងពិនិត្យបណ្តឹងតវ៉ានោះក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ។ ប្រសិនបើពាក្យបណ្តឹងតវ៉ានោះត្រូវបានផ្ញើមកក្នុងពេលកំពុង ពិនិត្យ

[19] -កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោកប្រធានអង្គភាពលទ្ធកម្ម ក្រុងច្បារមន (ដោយនិស្សិត ទូច លៀងហួរ និងខេង រ៉ឹងហួរ)

វាយតម្លៃសំណើដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មគ្រាន់តែទទួល និងយកមកពិចារណាក្នុងពេលកំពុង ដំណើរការវាយតម្លៃ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវឆ្លើយតបភ្លាមៗ ចំពោះពាក្យបណ្តឹងតវ៉ានោះ បន្ទាប់ពីការប្រគល់កិច្ចសន្យារួច។ ក្នុងករណីមិនពេញចិត្តនឹងចម្លើយដែលទទួលបានពីស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងរយៈ ពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ អ្នកដេញថ្លៃ ឬទីប្រឹក្សាមានសិទ្ធិប្តឹងបន្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ ឡើងវិញលើការសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវឆ្លើយតបក្នុងរយៈ ពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ានោះ។

សេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះពាក្យបណ្តឹងតវ៉ានេះ គឺជាសេចក្តីសម្រេច ចុងក្រោយ ប៉ុន្តែសេចក្តីសម្រេចនេះអាចជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅតុលាការបានក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើ ការគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច ហើយមិនប៉ះពាល់ដល់ការប្តឹងតវ៉ាណាមួយដែលមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទេ។ គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ អ្នកទទួលការសាងសង់ និងទីប្រឹក្សា នៅក្រោមកិច្ចសន្យាហិរញ្ញប្បទានសាធារណៈ ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈខ្ពស់បំផុត នៅក្នុងអំឡុងពេលជ្រើសរើស និងការអនុវត្តកិច្ចសន្យា។ រាជរដ្ឋាភិបាលមានសិទ្ធិធ្វើអធិការកិច្ច និងពិនិត្យឡើង វិញលើឯកសារដែលជាប់ពាក់ព័ន្ធនឹងការដេញថ្លៃ សំណើសុំដេញថ្លៃ និងកិច្ចសន្យារបស់អ្នកដេញថ្លៃ អ្នក ទទួលការ អ្នកផ្គត់ផ្គង់ និងទីប្រឹក្សាទាំងអស់។

៥.២.ការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មសាធារណៈ

កិច្ចសន្យាត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើវិវាទណាមួយដែលកើតឡើងរវាងភាគី ស្ថាប័នអនុវត្តលទ្ធកម្ម(អ្នកម្ចាស់ការ) និង ភាគី អ្នកទទួលការ អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬទាក់ទិននឹងការមិនគោរពតាមកិច្ចសន្យា ឬការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី អ្នកម្ចាស់ការ និងភាគី អ្នកទទួលការ មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបដែលត្រូវជ្រើសតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា។ ករណីដែលមានរឿងក្តីកើតឡើងបណ្តាលមកពី ភាគីណាមួយរំលោភលើលក្ខខណ្ឌនានានៃកិច្ចសន្យាភាគីនោះត្រូវទទួលខុសត្រូវចំពោះការចំណាយជួលមេធាវីនូវចំនួនទឹកប្រាក់១០% នៃចំនួនដែលបានទាមទារឱ្យសង។ ការចំណាយលើការខូចខាត និងចំណាយដទៃទៀតក្នុងរឿងក្តីនោះ ត្រូវបានបង្ខិតបង្ខំដោយច្បាប់។

ផ្នែកទី២ បញ្ហាប្រឈម និងដំណោះស្រាយ

១.បញ្ហាប្រឈម

បច្ចុប្បន្នរដ្ឋបាលក្រុងច្បារមនបានចាប់ផ្តើមអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសាធារណៈតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information Systems) ហៅកាត់ថា FMIS គឺជាប្រព័ន្ធស្វ័យប្រវត្តិកម្ម និង សមាហរណកម្មនូវដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាដែលរួមមាន ការរៀបចំនិងអនុវត្តថវិកា ប្រតិបត្តិការហិរញ្ញវត្ថុ ការរៀបចំរបាយការណ៍ការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្ម ជាដើម។ FMIS គឺជាប្រព័ន្ធស្នូលតែមួយគត់ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ រាល់ទិន្នន័យផ្លូវការដែលត្រូវប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលត្រូវផលិតចេញ ពី FMIS តែមួយគត់។[20]

ប្រព័ន្ធ FMIS មានគុណសម្បត្តិ និងគុណវិបត្តិដូចខាងក្រោម៖

- **គុណសម្បត្តិ**
  - ជួយពន្លឿន និង ផ្តល់ភាពងាយស្រួលដល់មន្ត្រី ក្នុងការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋបានឆាប់រហ័ស និងទាន់ពេលវេលា
  - ជាឧបករណ៍ដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់គ្រប់គ្រងព័ត៌មានចំណូល ចំណាយប្រកបដោយប្រសិទ្ធភាពខ្ពស់។
- **គុណវិបត្តិ**
  - ការអនុវត្តនីតិវិធីមានមុខងារច្រើនដែលពិបាកក្នុងការចូលប្រើប្រាស់
  - មន្ត្រីជំនាញលទ្ធកម្មសាធារណៈ និង មន្ត្រីដែលពាក់ព័ន្ធផ្សេងៗ នៅមិនទាន់ច្នឹកដៃក្នុងការប្រើប្រាស់តាមប្រព័ន្ធ(FMIS)នៅឡើយ
  - ការអនុវត្តត្រូវតែមកធ្វើផ្ទាល់នៅក្នុងការិយាល័យមិនអាចអនុវត្តពីចម្ងាយបានឡើយ។[21]

២.ដំណោះស្រាយ

- រដ្ឋបាលក្រុងគួរតែបង្កើតវគ្គបណ្តុះបណ្តាលដល់មន្ត្រីជំនាញលទ្ធកម្មសាធារណៈ និងមន្ត្រីដែលពាក់ព័ន្ធផ្សេងៗឱ្យយល់ច្បាស់ពីការអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសាធារណៈតាមរយៈប្រព័ន្ធកុំព្យូទ័រ
- ក្រុងគួរតែបង្កើតមុខងារដែលបានអនុវត្តពីចម្ងាយបាន ។

[20] -សៀវភៅគោលការណ៍ណែនាំរួមស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០២៤

[21]- កិច្ចសម្ភាសន៍ជាមួយលោកអភិបាលក្រុងច្បារមន (ដោយ និស្សិត ទូច លៀងហួរ)

សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចបំណងនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ គឺអាស្រ័យលើលទ្ធផលនៃការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ប្រព័ន្ធថវិកា។ បើតាមការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ដើម្បីកែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈឱ្យក្លាយជាប្រព័ន្ធមួយដែលកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងស្របតាមបទដ្ឋាន និងឧត្តមានុ វត្តន៍អន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់រយៈពេលវែងសំដៅជំរុញ កំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផលកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវ ប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ ជាពិសេសរួមចំណែកក្នុងការអនុវត្តតាមចក្ខុវិស័យ និងបំណងប្រាថ្នាដ៏ឧត្តុង ឧត្តមរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការកែប្រែ កម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ បានរួម ចំណែកក្នុងការបង្កើនតម្លាភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រងចំណាយរបស់រាជរដ្ឋាភិបាលដែលផ្តោតលើអាទិភាពខ្លាំងក្នុងកំណើនសេដ្ឋកិច្ចនៃការទ្រទ្រង់ វិស័យសង្គមកិច្ច សម្រាប់បម្រើឧត្តមប្រយោជន៍របស់ជាតិ និងប្រជាពលរដ្ឋទាំងមូល។

ដោយបានការសិក្សាស្រាវជ្រាវទៅលើអង្គច្បាប់ និងទទួលបានបទពិសោធន៍ក្នុងការសិក្សាស្រាវជ្រាវដោយផ្ទាល់ទៅលើកិច្ចក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងក្រុងច្បារមន ខេត្តកំពង់ស្ពឺ បាន បញ្ជាក់ឱ្យឃើញថា យន្តការនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈបានដើរតួយ៉ាងសំខាន់ក្នុង គោលនយោបាយ កំណែទម្រង់យ៉ាងស៊ីជម្រៅទៅលើរដ្ឋបាលសាធារណៈនៅកម្ពុជា ជាពិសេសលើគោលនយោបាយគ្រប់គ្រង ថវិកាជាតិ ដែលមានមុខព្រួញសំខាន់ផ្តោតទៅលើការពង្រឹងប្រសិទ្ធភាព នៃការប្រើប្រាស់ធនធាន និងថវិការ របស់រដ្ឋពីសំណាក់មន្ត្រីរាជការសាធារណៈ។ ម្យ៉ាងទៀតដោយផ្អែកទៅលើវិធីសាស្ត្រ នីតិវិធី ការតាមដាន និងត្រួត ពិនិត្យពីសំណាក់ស្ថាប័នគ្រប់គ្រងលទ្ធកម្ម និងការប្រតិបត្តិរបស់ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ បានធ្វើឱ្យយន្តការនៃការអនុវត្តលទ្ធកម្មសាធារណៈនៅក្នុងក្រុងច្បារមន ទទួលបាននូវសមិទ្ធផល និងប្រសិទ្ធភាពកាន់តែប្រសើរឡើងថែមទៀត។

អនុសាសន៍

អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងម៉ត់ចត់ពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្រុងច្បារមន រួចមកសរបញ្ជាក់ឱ្យឃើញថា ទោះជាមានការយកទុកចិត្តដាក់ពីសំណាក់ស្ថាប័នពាក់ព័ន្ធទៅលើកិច្ចការលទ្ធកម្មយ៉ាងណាក៏ដោយ ក៏នៅតែមានភាពអវិជ្ជមានខ្លះៗនៅតែបន្តកើតមានឡើងដដែល។ ដោយផ្អែកលើបញ្ហាប្រឈម និង សេចក្តីសន្និដ្ឋានខាងលើ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍ផ្ទាល់ខ្លួនខ្លះៗ ក្នុងការជួយពង្រឹងនូវការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងថ្នាក់ក្រុងឱ្យកាន់តែល្អប្រសើរថែមទៀត៖

- រាជរដ្ឋាភិបាលគួរតែផ្តល់នូវការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលពីការអនុវត្តនីតិវិធីនៃការធ្វើលទ្ធកម្មសាធារណៈតាមរយៈប្រព័ន្ធកុំព្យូទ័រដល់មន្ត្រីលទ្ធកម្មទាំងអស់
- អង្គភាពលទ្ធកម្មក្រុង គួរតែបង្ហាញតម្លាភាពឯកសារឱ្យបានច្រើន
- អង្គភាពលទ្ធកម្មក្រុង គួរតែបង្កើនការផ្តល់ការសហការក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិត
- រដ្ឋបាលក្រុងគួរបង្កើនការបណ្តុះបណ្តាលដល់មន្ត្រីបន្តផង។

ឯកសារយោង

ឯកសារយោង

- **ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។**
- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**
  - ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ នស/រកម/០៥២៣/០០៥។
  - **អនុក្រឹត្យ**
  - អនុក្រឹត្យលេខ ១០៥ អនក្រ.បក ស្តីពីលទ្ធកម្មសាធារណៈ ចុះថ្ងៃទី ១៨ ខែតុលាឆ្នាំ២០០៦
  - អនុក្រឹត្យលេខ២១ អនក្រ.បក ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ចុះថ្ងៃទី២១ ខែកុម្ភៈឆ្នាំ២០១៨ ។
  - **ប្រកាស**
  - ប្រកាសលេខ ៩៨៧ សហវ.ប្រក ស្តីពីក្រមសីលធម៌លទ្ធកម្ម
  - ប្រកាសលេខ ១៦១៣ សហវ.ប្រក ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ
  - ប្រកាសលេខ ០១០ សហវ.ប្រក ស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៩
  - ប្រកាសលេខ៩៨៦ សហវ.ប្រកស្តីពីប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
  - ប្រកាសលេខ ១៦១៤ សហវ.ប្រកស្តីពីនីតិវិធីនៃការចុះការការជម្រះនិងការផ្សព្វផ្សាយបញ្ជីខ្មៅ
  - ប្រកាសលេខ ១៣២៧ សហវ.ប្រក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចុះថ្ងៃទី១១ធ្នូ ឆ្នាំ២០១៣
  - ប្រកាសលេខ ២៨៩សហវ.ប្រកស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
  - ប្រកាសលេខ ៩៨៨ សហវ.ប្រកស្តីពីការដាក់ឱ្យប្រើសៀវភៅណែនាំស្តីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ
  - ប្រកាសលេខ៨៥១ សហវ.ប្រក ស្តីពីការរៀបចំផែនការលទ្ធកម្ម
  - ប្រកាសស្តីពីឥណទានថវិកាប្រកាស លេខ ១៩១១ សហវ.ប្រក ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីអំពីនីតិវិធីអនុវត្តថវិកាកម្មវិធី
  - ប្រកាសលេខ ៣២៦ ប្រគល់ស្តីអំពីការកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម

- ប្រកាសលេខ ៣២៥ សហវ.ប្រក ស្តីពីការដាក់ប្រើប្រាស់គំរូឯកសារដេញថ្លៃពិគ្រោះនិងស្នង់តម្លៃ សម្រាប់ លទ្ធកម្មទំនិញនិងសំណង់ចុះថ្ងៃទី ២៦ ខែមីនាឆ្នាំ២០១៤
- ប្រកាសអន្តរក្រសួងលេខ៥៦៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែឧសភាឆ្នាំ ២០០៤ស្តីពីការប្រគល់សេចក្តី សម្រេចលើកិច្ចលទ្ធកម្មសាធារណៈទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ
- ប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសាឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានីខេត្ត ក្រុងស្រុក ខណ្ឌ
- ប្រកាសលេខ ២៩៨ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលការរៀបចំ និងការ ប្រព្រឹត្តទៅនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ៤០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែឧសភាឆ្នាំ ២០០៦ ស្តីពីការអនុវត្តវិធីសាស្ត្រលទ្ធកម្ម
- ប្រកាសលេខ ៤០៥ សហវ.ប្រក ស្តីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈចុះថ្ងៃទី៣០ ខែមករាឆ្នាំ ២០០៥
- ប្រកាសលេខ ៣៦៣ សហវ-លស-ប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីអ្នក ទទួលការសាងសង់ចុះថ្ងៃទី ១៤ ខែវិច្ឆិកាឆ្នាំ ១៩៩៥ ។
- ប្រកាសលេខ ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីកាតកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម (ក្រសួង ស្ថាប័ន រាជធានី ខេត្ត)

- **សារាចរណែនាំ**
  - សារាចរណែនាំលេខ ០០៦ សហវ.ប្រក ស្តីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩
  - សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី ០៥ ខែមិនាឆ្នាំ ២០១៩ ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃ និង ការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា និងកិច្ចលទ្ធកម្មសាធារណៈ
  - សារាចរណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី06 ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  - សារាចរណែនាំលេខ ០១៥ សហវ ចុះថ្ងៃទី២៥ ឆ្នាំ ២០១៥ អំពីការរឹបអូសប្រាក់កកក្នុងដំណើរការកិច្ចលទ្ធ កម្មនៅរដ្ឋបាលក្រុងស្រុកខណ្ឌ

- សារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីអំពីការអនុវត្តលទ្ធកម្ម សាធារណៈសម្រាប់មុខទំនិញនិងសេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់នៅដើមឆ្នាំ ថវិកា
- សារាចរណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ស្តីពីការអនុវត្ត កិច្ចលទ្ធកម្ម សាធារណៈ
- សារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការរៀបចំផែនការ លទ្ធកម្មក្នុងឆ្នាំ ២០០៨ និងឆ្នាំបន្តបន្ទាប់សារាចរណែនាំលេខ ០០១ សហវ.សរណចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្ម សាធារណៈ
- សារាចរណែនាំលេខ ០១២ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០០៦ ស្តីពីផែនការលទ្ធកម្ម
- សេចក្តីណែនាំលេខ ០១៤ ស្តីពីនីតិវិធីសម្រាប់ធ្វើបុរេលក្ខណៈសម្បត្តិអ្នកដេញថ្លៃ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៩
- សេចក្តីណែនាំលេខ ០១៣ សហវ ស្តីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នក ទទួលការសាងសង់។

- **សៀវភៅ**
  - សៀវភៅលទ្ធកម្មស្តីអំពីការអនុវត្តវិធាននិងបទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ
  - សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូនិធិឃុំ សង្កាត់
  - សៀវភៅលទ្ធកម្មស្តីពី ការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ
  - សៀវភៅណែនាំស្តីពី ការគ្រប់គ្រងកិច្ចការរដ្ឋបាលក្រុង ស្រុក ចេញដោយ ក្រសួងមហាផ្ទៃ ឆ្នាំ២០២៣។
  - សៀវភៅលទ្ធកម្មសាធារណៈនៅកម្ពុជា ស្រាវជ្រាវដោយ **ឡាញ់ ដា** បោះពុម្ពលើកទី១ ឆ្នាំ២០២២ ។

- **ឯកសារជាខេមរភាសារដកស្រង់ពីអ៊ីនធើណេត**
  - https://km.m.wikipedia.org/wiki/ក្រុងច្បារមន
  - http://gdpp.gov.kh/
  - https://www.mef.gov.kh/
  - http://gdpp.gov.kh/about-gdpp/department-of-sub-national-administrative-procurement-management/
  - https://opendevelopmentcambodia.net/km/topics/procurement/

ឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ ផែនទីរដ្ឋបាល និង ហេដ្ឋារចនាសម្ព័ន្ធ ក្រុងច្បារមន ខេត្ត កំពង់ស្ពឺ
- ឧបសម្ព័ន្ធទី២ ការិយាល័យអង្គភាពលទ្ធកម្ម ក្រុងច្បារមន
- ឧបសម្ព័ន្ធទី៣ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- ឧបសម្ព័ន្ធទី៤ ប្រកាសលេខ ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម (ក្រសួង ស្ថាប័ន រាជធានី ខេត្ត)
- ឧបសម្ព័ន្ធទី៥ សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៤ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា
- ឧបសម្ព័ន្ធទី៦ សេចក្តីណែនាំ លេខ ០៣៤ អណន ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំបង្កើតគណៈកម្មធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ឧបសម្ព័ន្ធទី៧ គម្រូសេចក្តីសម្រេចស្តីពី ការកែសម្រួលគណៈកម្មាធិការលទ្ធកម្មរបស់ក្រុមប្រឹក្សាក្រុងច្បារមន ខេត្តកំពង់ស្ពឺ
- ឧបសម្ព័ន្ធទី៨ សារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពី ការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ផែនទីរដ្ឋបាល និង ហេដ្ឋារចនាសម្ព័ន្ធ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ



ឧបសម្ព័ន្ធទី២ ការិយាល័យអង្គភាពលទ្ធកម្ម ក្រុងច្បារមន



ឧបសម្ព័ន្ធទី៣

ឧបសម្ព័ន្ធទី៤

ប្រកាសលេខ ១៨៦៦ សហវ.ប្រក

ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤

ស្តីពី

ការកម្រិតទឹកប្រាក់សម្រាប់

អនុវត្តវិធីសាស្ត្រលទ្ធកម្ម

(ក្រសួង ស្ថាប័ន រាជធានី ខេត្ត)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ១៨៥៦....សហវ...

ប្រកាស
ស្តីពី
ការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩១៣/៥០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សម្រេច

ប្រការ១.-

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មចំនិញ សំណង់ និងសេវាកម្ម នៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

ប្រការ២.-

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មចំនិញ សំណង់ និងសេវាកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

ប្រការ៣.-

ហាមបំបែកគម្រោងជាគម្រោងតូច១ ក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ដូចខ្លឹមសារដែលមានចែងក្នុងមាត្រាពាក្យ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

ប្រការ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៥.-

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល និងប្រធានអង្គភាពចំណុះក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ ភ្នំ ឆ្នាំ២០១៤

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាស
លេខ១៥៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែ ក្ញ ឆ្នាំ ២០១៤

តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
នៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល

វិធីសាស្ត្រ	កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម		
	ទំនិញ	សំណង់	សេវាកម្ម
ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ)	ចាប់ពី ៥.០០០លានរៀលឡើង	ចាប់ពី ៦.០០០លានរៀលឡើង	ចាប់ពី ៤.០០០លានរៀលឡើង
ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក(ដ.ប.ស)	ចាប់ពី ១០០លានរៀល ដល់ក្រោម ៥.០០០លានរៀល	ចាប់ពី ១០០លានរៀល ដល់ក្រោម ៦.០០០លានរៀល	ចាប់ពី ១០០លានរៀល ដល់ក្រោម ៤.០០០លានរៀល
ការដេញថ្លៃមានកម្រិត(ដ.ក)	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់
ការពិគ្រោះថ្លៃ(ព.ថ)	ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល	ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល	ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល
ការស្ទង់តម្លៃ(ស.ត)	ក្រោម ២០លានរៀល	ក្រោម ២០លានរៀល	ក្រោម ២០លានរៀល
លទ្ធកម្មដោយឡែក(ល.ឡ)	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់

ឧបសម្ព័ន្ធទី២នៃប្រកាស
លេខ១៨៦៦សហវ.ប្រក ចុះថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០១៤

តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

វិធីសាស្ត្រ	កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម		
	ឥន្ទិញ	សំណង់	សេវាកម្ម
ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ)	ចាប់ពី ២.០០០លានរៀល ឡើង	ចាប់ពី ២.៥០០លានរៀល ឡើង	ចាប់ពី ១.៥០០លានរៀល ឡើង
ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក(ដ.ប.ស)	ចាប់ពី ១០០លានរៀល ដល់ក្រោម ២.០០០លានរៀល	ចាប់ពី ១០០លានរៀល ដល់ក្រោម ២.៥០០លានរៀល	ចាប់ពី ១០០លានរៀល ដល់ក្រោម ១.៥០០លានរៀល
ការដេញថ្លៃមានកម្រិត(ដ.ក)	មិនមានកម្រិតទឹកប្រាក់	ចិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់
ការពិគ្រោះថ្លៃ(ព.ថ)	ចាប់ពី ១០លានរៀល ដល់ក្រោម ១០០លានរៀល	ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល	ចាប់ពី ១០លានរៀល ដល់ក្រោម ១០០លានរៀល
ការស្នងតម្លៃ(ស.ត)	ក្រោម ១០លានរៀល	ក្រោម ២០លានរៀល	ក្រោម ១០លានរៀល
លទ្ធកម្មដោយឡែក(ល.ឡ)	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់

ឧបសម្ព័ន្ធទី៥

សារាចរណែនាំលេខ ០១៣ សហវ

ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៤

ស្តីពី

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់

មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន

ដែលត្រូវប្រើប្រាស់បន្ទាន់ដើមឆ្នាំថវិកា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៦៨៣.....សហវ.....

សារាចរណែនាំ

ស្តីពី

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ
និងសេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា

ក្នុងគោលបំណងឆ្លាទាឱ្យក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពថវិកា និងអង្គភាពរដ្ឋដទៃទៀតមានមុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន សម្រាប់ប្រើប្រាស់ទាន់ពេលវេលានៅដើមឆ្នាំនៃឆ្នាំថវិកានីមួយៗ ដើម្បីបង្កើនល្បឿននិងប្រសិទ្ធភាពនៃចំណាយថវិកាជាតិ ព្រមទាំងបង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈឆាប់រហ័ស និងនៅតែធានាបានន្ទវត្ថាភាព គណនេយ្យភាព ព្រមទាំងការសន្សំសំចៃក្នុងដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈស្របតាមបទប្បញ្ញត្តិនៃច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពថវិកា និងអង្គភាពរដ្ឋដទៃទៀត ចាប់ពីឆ្នាំ២០១៦ តទៅត្រូវអនុវត្តដូចខាងក្រោម÷

១. ត្រូវរៀបចំគម្រោងនិងស្នើសុំធានាចំណាយថវិកាឆ្នាំបន្ទាប់ (ឆ្នាំ N+1) សម្រាប់ការទិញទំនិញ និងសេវាកម្មចាំបាច់និងមានលក្ខណៈជាប្រចាំមួយចំនួនរួមមានជាអាទិ៍÷ សម្ភារការិយាល័យ សៀវភៅសិក្សាគោលនិងកម្មសិទ្ធិបញ្ញា ឯកសណ្ឋាន អាវយឺត (សម្រាប់ទិវាបុណ្យសិទ្ធិនារីផមីនា) ឱសថ បរិក្ខារពេទ្យ ប្រេងឥន្ធនៈ អង្ករ មី ត្រីខ ចំណីសត្វ និងសេវាសម្អាត មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត នៅក្នុងត្រីមាសទី៤នៃឆ្នាំ N។

២. ត្រូវស្នើសុំធានាចំណាយដោយឈរលើមូលដ្ឋាន៥0% នៃមុខចំណាយនីមួយៗនៃកញ្ចប់ថវិកាឆ្នាំ N លើកលែងតែក្រសួងមហាផ្ទៃនិងក្រសួងការពារជាតិសម្រាប់ការទិញអង្ករនិងឯកសណ្ឋាន និងក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការបោះពុម្ពសៀវភៅសិក្សាគោលនិងកម្មសិទ្ធិបញ្ញា ដែលអាចអនុញ្ញាតឱ្យស្នើសុំធានាចំណាយច្រើនបំផុតត្រឹម ១00% នៃថវិកាឆ្នាំN។

៣. ត្រូវរួសរាន់ដំណើរការរៀបចំកិច្ចលទ្ធកម្មសាធារណៈដើម្បីទទួលបានទំនិញ ឬសេវាកម្ម មកប្រើប្រាស់តាមការគ្រោងទុកនៅពេលដែលទទួលបានធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤. ត្រូវស្នើសុំទូទាត់ជាដំណាក់ៗក្នុងត្រីមាសនីមួយៗនៃឆ្នាំ N+1 ក្រោយពីមានការប្រគល់ទទួលទំនិញ ឬសេវាកម្មជាក់ស្តែង។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៥. ត្រូវកត់ត្រាគម្រោងចំណាយលើមុខទំនិញ និងសេវាកម្ម ដែលបានអនុវត្តកិច្ចលទ្ធកម្មក្នុងត្រីមាសទី៤ នៃឆ្នាំ N ដោយប្រើប្រាស់កញ្ចប់ថវិកាឆ្នាំ N+1 នៅក្នុងការរាងផែនការលទ្ធកម្មប្រចាំឆ្នាំ N+1។

៦. ត្រូវអនុវត្តតាមសារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្រៅពីមុខទំនិញ និងសេវាកម្មដូចបានកំណត់ក្នុងចំណុចទី១ខាងលើ។

គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពថវិកា និងអង្គភាពរដ្ឋដទៃទៀត ត្រូវទទួលបន្ទុកអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១៥

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

ឈឿក អុន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការកាជវាំងតិចបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី៦

សេចក្តីណែនាំ លេខ ០៣៤ អណន

ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៣

ស្តីពី

ការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ឧបសម្ព័ន្ធទី៧

គម្រោងសេចក្តីសម្រេច

ស្តីពី

ការកែសម្រួលគណៈកម្មាធិការលទ្ធកម្ម

របស់ក្រុមប្រឹក្សាក្រុងច្បារមន ខេត្តកំពង់ស្ពឺ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកំពង់ស្ពឺ
រដ្ឋបាលក្រុងច្បារមន

លេខ.....សសរ

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលគណៈកម្មាធិការលទ្ធកម្មរបស់ក្រុមប្រឹក្សាក្រុង
ក្រុមប្រឹក្សាក្រុងច្បារមន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស០៥០៨/០១៧ចុះថ្ងៃទី២៤ខែឧសភា ឆ្នាំ២០០៨ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែ មករាឆ្នាំ ២០១២ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ ប.ក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៩ស្តីពីតួនាទីភារៈកិច្ច និង ទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦១២ អនក្រ.តត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងច្បារមន
- បានឃើញអនុក្រឹត្យលេខ៤៧៣ អនក្រ.តត ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការតែងតាំង អភិបាល នៃគណៈអភិបាលក្រុងច្បារមន ខេត្តកំពង់ស្ពឺ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមសេចក្តីជូនដំណឹងលេខ៦៥៤សដណ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌ គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខណ្ឌ និងក្រុមការងារពាក់ព័ន្ធ
- យោងស្មារតីប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងលើកទី៣៤ អាណត្តិទី៣ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២
- ទទួលបានការអនុម័តពីក្រុមប្រឹក្សាក្រុងក្នុងកិច្ចប្រជុំសាមញ្ញលើកទី

សម្រេច

ប្រការ ១ៈ ត្រូវបានបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុងដែលមានសមាសភាពដូចខាងក្រោម ៖

១. លោក	**ហុក ម៉ាឃីន**	អភិបាលក្រុង	ប្រធាន
២. លោក	**ជាត សុផល**	អភិបាលរងក្រុង	អនុប្រធាន
៣. លោក	**រៀម សារ៉ាត**	សមាជិកក្រុមប្រឹក្សាក្រុង	សមាជិក
៤. លោកស្រី	**ម៉ិច ស៊ីយឿន**	សមាជិកក្រុមប្រឹក្សាក្រុង	សមាជិក
៥. លោក	**អ៊ុម ចាន់តារា**	នាយករដ្ឋបាលក្រុង	សមាជិក

៦.	លោកស្រី	**សាយ រស្មី**	អនុប្រធានការិ.រដ្ឋបាល ហិរញ្ញវត្ថុ	សមាជិក
៧.	លោក	**ចាន់ រតនៈ**	ប្រធានអង្គភាពលទ្ធកម្ម	លេខាធិការ

ប្រការ ២៖ គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង មានតួនាទី និងភារៈកិច្ចសំខាន់ៗដូចខាងក្រោម៖

-គោរពឲ្យបានខ្ជាប់ខ្ជួនតាមក្រមសីលធម៌លទ្ធកម្ម

-ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រៀងផែនការលទ្ធកម្មប្រចាំឆ្នាំដែលរៀបចំដោយអង្គភាពលទ្ធកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាពមុននិងផ្ញើជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងអនុមត័

-ណែនាំឲ្យអង្គភាពលទ្ធកម្មអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម

-ប្រជុំវាយតម្លៃ កំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ

-ត្រួតពិនិត្យឡើងវិញលើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗមុននឹងចាប់ផ្តើមដំណើរការលទ្ធកម្ម

-ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន

-ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ

-ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា

-ត្រួតពិនិត្យនិងវាយតម្លៃឡើងវិញលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ មុនការប្រគល់សម្រេចប្រគល់កិច្ចសន្យា

-ជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះ និង ចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់

-ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ

-រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ តាមការចាំបាច់ និង ការកំណត់របស់ក្រុមប្រឹក្សា

-ធ្វើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស បីង ប្រចាំឆ្នាំជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុមត័ដោយក្រុមប្រឹក្សារបស់ខ្លួន

-ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ៣ ៖ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤ ៖ គណៈអភិបាលក្រុង នាយករដ្ឋបាលក្រុង អង្គភាពនានាចំណុះឲ្យសាលាក្រុងច្បារមន លោក លោកស្រី ដូចមានរាយនាមក្នុងប្រការ១ខាងលើ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.....ខែ.....ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ច្បារមន ថ្ងៃទី.....ខែ..... ឆ្នាំ២០២២

ស.ក្រុមប្រឹក្សាក្រុង
ប្រធាន

ចម្លងជូន
- រដ្ឋបាលខេត្តកំពង់ស្ពឺ
- ការិអង្គភាពជុំវិញក្រុង "ដើម្បីជូនជ្រាប"
- ដូចក្នុង១ និងប្រការ៤ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី៨

សារាចរណែនាំលេខ ០០៦ សហវ

ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩

ស្តីពី

ការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៦.....សហវ.....

សារាចរណែនាំ

ស្តីពី

ការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ

ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការរៀបចំថវិកាសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ស្របតាមការចង្អុលទិសនៃឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ដូចខាងក្រោម÷

១. ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាត្រូវរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយឆ្លុះបញ្ចាំងអំពីតម្រូវការប្រើប្រាស់ចាំបាច់និងអាទិភាពនៃតម្រូវការចំណាយនិងផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំនេះត្រូវបញ្ជាក់ឈ្មោះគម្រោង តម្លៃគម្រោង វិធីសាស្ត្រលទ្ធកម្ម កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់នៃការអនុវត្តគម្រោង និងកាលបរិច្ឆេទគ្រោងទូទាត់។

២. អង្គភាពប្រើប្រាស់នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាត្រូវរៀបចំតម្រូវការតម្រូវការប្រើប្រាស់ប្រចាំឆ្នាំតាមប្រភេទលទ្ធកម្ម រួមមានលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដោយបញ្ជាក់អំពីបរិមាណ តម្លៃ លក្ខណៈបច្ចេកទេស និងពេលវេលាប្រើប្រាស់ រួចបញ្ជូនឱ្យបានទាន់ពេលវេលាទៅអង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្មដើម្បីបូកសរុបទិន្នន័យនៃតម្រូវការប្រើប្រាស់។

៣. អង្គភាពលទ្ធកម្ម នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងក្រុមលទ្ធកម្មនៃអង្គភាពថវិកាត្រូវរៀបចំជាឡត់លទ្ធកម្ម សម្រាប់មុខសញ្ញាលទ្ធកម្មដែលស្ថិតក្នុងប្រភេទដូចគ្នាហើយមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឱ្យការងារតែមួយ។ ឡត់លទ្ធកម្មដែលមានលក្ខណៈដូចគ្នាឬស្រដៀងគ្នាត្រូវបញ្ចូលជាក្រុមធំមួយហៅថាកញ្ចប់លទ្ធកម្មឬគម្រោងលទ្ធកម្មសម្រាប់ធ្វើលទ្ធកម្មតែមួយលើក បន្ទាប់មកត្រូវគណនាតម្លៃនិងកំណត់វិធីសាស្ត្រលទ្ធកម្មនៃគម្រោងនីមួយៗនោះ។

៤. អង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងក្រុមលទ្ធកម្មនៃអង្គភាពថវិកា ត្រូវរៀបចំជាតារាងគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំតាមគំរូដែលជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ។ ដោយឡែកអង្គភាពថវិកាថ្នាក់កណ្តាលនិងអង្គភាពថវិកាថ្នាក់មូលដ្ឋាននៃស្ថាប័នអនុវត្តលទ្ធកម្មថ្នាក់ជាតិត្រូវបញ្ជូនគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំទៅអង្គភាពលទ្ធកម្មនៃសាមីស្ថាប័នអនុវត្តលទ្ធកម្មដើម្បីបញ្ចូលជាឧបសម្ព័ន្ធនៃគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម តាមគំរូដែលជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ ឱ្យបានក្នុងសប្តាហ៍ទី១ នៃខែមិថុនា មុនឆ្នាំអនុវត្តថវិកា។

៥. ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំភ្ជាប់ជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួនពីរច្បាប់ ដោយមួយច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងមួយច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានថវិកា យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមិថុនា មុនឆ្នាំអនុវត្តថវិកា សម្រាប់ជាមូលដ្ឋានក្នុងការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ កម្រិតបច្ចេកទេសនិងកម្រិតថ្នាក់ដឹកនាំក្រសួងស្ថាប័នជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការខកខានមិនបានភ្ជាប់គម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំដែលជាសមាសធាតុសំខាន់មួយធ្វើឱ្យការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំនឹងមិនអាចប្រព្រឹត្តទៅបាន។

៦. ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាត្រូវកែសម្រួលគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយកញ្ចប់ថវិកាបន្ទាប់ពីបានឯកភាពក្នុងពេលការពារថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយរៀបចំជាសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដោយត្រូវអនុលោមតាមប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី៣ ខែវិច្ឆិកា ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកា ត្រូវទទួលបន្ទុកអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ៧ ដែ ១ ទៀ ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៩

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ